# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ឹម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ទំព័រ

ផ្នែកអក្សរសា

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម .... ព្រះរាជក្រឹត្យ កំណត់ព្រំប្រទល់ស្រុក....... ៦០៧
ពង្សាវតារប្រទេសចិន (តមក)...... ៦២០
" " " 
ឧកញ៉ា ទេពពិទូរ-ក្រសេម.... វណ្ណគតិ ឆាកយាណ៍ ទសាវតារ (តមក).. ៦២៣
ឃុនឧត្តមប្រីជា ចាប-ពិន .. គតិប្បាយសុភាសិតខ្មែរ (តមក)...... ៦៣៦

ផ្នែកសាសនា

ឃុនបណ្ណាធិរក្ស ប៊ូ-ប៊ូ..... កំឡាំង ៥ យ៉ាង.............. ៦៤៩
ព្រះអាចារ្យ ហ៊ាង-ទាត់ .... អរិយសច្ចជាពុទ្ធភាសិត (តមក)..... ៦៥៣

ឆ្នាំទី ១៧ លេខ ១០ ខែឧក្តូប្រ៍ ១៩៤៥ - ថ្លៃជាវៈ ១ ឆ្នាំ ១៥ រៀល ៗ
1945
N° 10

# ព្រះរាជក្រឹត្យ

## ក្រមទៅហ្វាយស្រុក

ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាធិបតី (ព្រះអង្គច័ន្ទ)

(គ្រិស្តសករាជ ១៨២៨)

## សេចក្ដីផ្ដើម

ព្រះរាជក្រឹត្យ ក្រមទៅហ្វាយស្រុកនេះកើតឡើង ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាធិបតី (ព្រះអង្គច័ន្ទ) នៅក្នុងឆ្នាំមហាសករាជ ១៧៥១ ឆ្នាំ គឺក្នុងពុទ្ធសករាជ ២៣៧១ ក្រោយឆ្នាំដែលទ្រង់បានឡើងគ្រងរាជសម្បត្តិជាច្រើនឆ្នាំ ព្រោះតាមព្រះរាជពង្សាវតារថា ព្រះករុណាជាអម្ចាស់ជីវិតព្រះអង្គនេះ ទ្រង់បានរាជាភិសេកគ្រប់គ្រងរាជសម្បត្តិ នៅថ្ងៃចន្ទ ៥ កើត ខែពិសាខ ឆ្នាំខាល ... ស័ក ពុទ្ធសករាជ ២៣៤៩ ត្រូវនឹងគ្រិស្តសករាជ ១៨០៦ ហើយបានទ្រង់រាជ្យរហូតមក ដល់ពុទ្ធសករាជ ២៣៧៧ គ្រិស្តសករាជ ១៨៣៤ ទើបទ្រង់សោយព្រះទិវង្គតដោយព្រះរោគចុះព្រះលោហិត (នៅថ្ងៃ ៥ កើត ខែបុស្ស ឆ្នាំមមីឆស័ក) រួមព្រះជន្មាយុ ៤៤ ទ្រង់គង់នៅក្នុងរាជសម្បត្តិ ២៨ ព្រះវស្សា ។

ក្នុងរជ្ជកាលនៃព្រះករុណាជាអម្ចាស់ជីវិតព្រះអង្គនេះ កម្ពុជរដ្ឋទាំងមូលប្រែប្រួលដោយសេចក្ដីវិបត្តិអន្តរាយផ្សេងៗ ជាច្រើនគ្រា ដូចជា កើតចលាចលខាងក្នុងស្រុក កើតចម្បាំងរាំរ៉ៃនឹងប្រទេសជិតខាង កើតវែកញែកខ្ញែកគ្នាក្នុងក្រុមព្រះរាជវង្សនិងពួកមន្ត្រី ក្រៅពីនេះ

នៅមានអគ្គិភ័យ ចោរភ័យ ឧទកភ័យនិងទុព្ភិក្ខភ័យកើតឡើង ក្នុងប្រទេសកម្ពុជាក្នុងគ្រានោះផង ៗ អស់លោក-អ្នកដែលបានមើលព្រះរាជពង្សាវតារក្រុងកម្ពុជាកាលនោះ គង់នឹកអាណោចអាធ័មក្នុងចិត្តនឹងកម្មគ្រាស់របស់ក្រុងកម្ពុជាក្នុងគ្រានោះជាអនេកពុំខាន ៗ តាមចំនួនសេចក្តីវិបត្តិអន្តរាយនានា ក្នុងគ្រានោះ គួរតែក្រុងកម្ពុជាដល់នូវការសាបសូន្យទៅហើយ បណ្តាជនជាតិខ្មែរក្នុងសម័យនោះ គង់នឹកឃើញយល់ថាកម្ពុជា គង់មិនមានជីវិតរស់នៅបានយូរអង្វែងរហូតមកដល់សព្វថ្ងៃនេះទេ ។ ហេតុនេះ ទើបយើងគួរសរសើរដល់កំពូលសំណាងរបស់កម្ពុជាទាក់ដែលមិនបានលិចលង់អន្តរាយទៅ នៅឱកាសដែលមានខ្យល់ព្យុះយ៉ាងធំក្នុងកាលនោះឡើយ ដោយពួកបុព្វបុរសរបស់យើងខំប្រឹងប្រែងទប់ទល់ជួសជុលការពារកេរ្តិ៍ក្រៀងៗ មកជាប្រចាំតំណរាជ្យ រហូតធ្លាក់មកដល់សម័យឯករាជ្យសព្វថ្ងៃនេះ ។

*

* *

ចំពោះព្រះរាជក្រឹត្យនេះ មានសេចក្តីផ្តើមថា ព្រះបាទសម្តេចព្រះឧទ័យរាជាធិបតី ទ្រង់មានព្រះបន្ទូលពិសេសចំពោះអ្នកចៅហ៊ីទល្ហៈ (សួស) តែអ្នកចៅហ៊ីមិនបានចាត់ចែងតែក្រោយព្រះរាជក្រឹត្យនេះឡើងជាថ្មីទេ គឺបានចាត់ឲ្យអ្នកឧកញ៉ាមហាទេព (មាស) ឲ្យស្ទុះស្វែងរកព្រះច្បាប់

ក្រមពៅហ្វាយស្រុកអំពីបុរាណយកមកស្រង់ចម្លងទៅវិញ ។ សេចក្ដីនេះ សឲ្យយើងយល់ថា ព្រះរាជក្រឹត្យក្រមពៅហ្វាយស្រុកនេះ ជាច្បាប់ចាស់ ដែលមានមកមុនរជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាជាយូរខែឆ្នាំ ឬ ច្រើនតំណពីដ្យមកហើយ ឬមួយអាចជាគេត្រៀមកែជាប់គងមកតាំងអំពី សម័យមហានគរធំ—វត្ត ក៏សឹងថាពុំត្រូវ ដោយការបោះបម្លងៗ តាមគ នឹងកែប្រែសេចក្ដីខ្លះតម្រូវទៅតាមពេលសម័យប៉ុណ្ណោះ ។ ពោះបីការ ស្រង់ចម្លងក្រមពៅហ្វាយស្រុកនេះ ក្នុងរជ្ជសម័យព្រះបាទសម្ដេចព្រះ ឧទ័យរាជានោះក៏គង់តែមានការកែប្រែខ្លះមិនខានទេ ដើម្បីតម្រូវទៅតាម កាលសម័យដូចពោលមកហើយ ។

មួយទៀត ពាក្យពេចន៍សំដីក្នុងក្រមពៅហ្វាយស្រុកនេះ យើង យល់ថាមានជាច់ពាក្យចាស់បុរាណមកខ្លះ ដូចសេចក្ដីចាប់ផ្ដើមថា: "សុក-មស្តុ សួស្តីសិរីសុភមង្គលាជយាតិរេក ១៧៥១ ស័ក ឆ្លូវនក្សត្រ ១ កើត មាឃមាស ព្រហស្បតិ៍វារសោរនោមត្តិ . . . ." នេះសឹងមានចំនួនលំនាំ ប្រហែលគ្នានឹងសិលាចារឹកខ្មែរវត្តជាច្រើនអន្លើ ក្នុងសតវត្សរ៍ទី ១៥-១៦ នៃគ្រិស្តសករាជ ។ ឯរបៀបរៀបរៀងសេចក្ដីនៃក្រមនេះ មានលំនាំ តាមការនិយមកប់កាន ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះឧទ័យរាជាទ្រង់ឯង សឹងមិនសូវជាប្លែកគ្នានឹងរបៀបសេចក្ដីក្នុងសម័យបច្ចុប្បន្ននេះប៉ុន្មានទេ ប៉ុន្តែធុជាសេសេចក្ដីនៃសម័យនោះ នឹងសម័យនេះខុសប្លែកពីគ្នាច្រើន ។

ឯព្រះរាជក្រឹត្យដែលយើងបានស្រង់ចម្លងចេញមកនេះ ច្បាប់ដើម ជាច្បាប់សាស្ត្រា រឹតតែ នៅមានក្នុងក្រាំងច្បាប់ មានដាក់ឈ្មោះអ្នកចម្លងពិកផ្សែ (ពេជ) តែគ្មានដាក់ថ្ងៃ-ខែ-ឆ្នាំនិងសករាជ ដែលគេបានចារចម្លងទេ ប៉ុន្តែបើសន្និដ្ឋានតាមចំណាស់របស់ស្លឹក ដែលចាស់គ្រាំគ្រាជាច្រើនហើយ ប្រហែលជាមានអាយុកន្លងមកតាំង ៧០-៨០ ឆ្នាំមកហើយៗមុននេះឡើងទៅទៀត ៕

*
*   *

មុខគួរឲ្យនឹកស្តាយពន់ពេក កាលណា យើងបានពិនិត្យមើលក្បួនច្បាប់ចាស់ៗ ដែលចារនឹងស្លឹករឹតទាំងឡាយ ទើបឃើញថា របៀបដាក់អក្សរខុសត្រូវហាក់ដូចជាគេមិនសូវយកចិត្តទុកដាក់ប៉ុន្មានសោះ (ទោះបីប៉ុន្មានទៅ មុននេះ មុនកើតវចនានុក្រមខ្មែរ ខ្មែរ យើងក៏មិនសូវជាយកចិត្តទុកដាក់នឹងរបៀបអក្សរខុសត្រូវ) បណ្តាពាក្យខ្មែរដែលមានកំណើតពាក្យចេញមកពីបាលីក្តី សំស្ក្រឹតក្តី គមិនបាច់សរសេរតម្រូវទៅតាមរបៀបច្បាប់អក្សរនៃភាសានោះៗទេ ក៏ជាភាសាខ្មែរមួយៗ ក៏ច្រើនតែសរសេរតាមតែបានដែរ ហ្នឹងហើយ អក្សរសាស្ត្រខ្មែរទៅជាភាសាឥតរបៀបរៀបរែង ដោយហេតុនេះសឲ្យឃើញថា របៀបអក្សរសាស្ត្រខ្មែរបានទៀតកើយដុនដាបជាច្រើនសតវត្សរ៍មកហើយ ។ មួយទៀត ក្បួនច្បាប់

ដែលអស់លោកអ្នកធ្លាប់បានរៀនរៀងហើយ ឬដែលបានសរសេរចម្លង ដោយចៃដន្យការនោះ គង់ឃើញច្បាប់ការប្រៀបធៀបគ្រលួ ប៉ុន្តែដូចជា ចម្លងតៗមកទៀត ដោយខ្វះ[illegible]នឹងភាពធ្លាប់ទាន់អក្សរសាស្ត្រ គ្រាន់តែមានចំណេះចេះអានអក្សរខ្មែរប៉ុណ្ណោះ រមែងក្រៀងឃ្លៀងឃ្លាត ពីច្បាប់ដើមទៅជាធម្មតា (នេះមិនបានប៉ះពាល់ដល់របៀបកែប្រែអក្សរសាស្ត្រ តាមយុគតាមសម័យទេ) ។

ដោយហេតុដែលបានពោលមកនេះ ការចម្លងបញ្ចោះពុម្ពនេះ ទើបត្រូវតែដាក់អក្សរតាមរបៀបថ្មីទាំងអស់ ដើម្បីឲ្យស្រួលមើលស្រួលអាន ។ ប្រសិនបើជាចង់ស្រាវជ្រាវតាមរបៀបអក្សរបូរាណនោះ មុខជាអស់លោកមើលបាន ដោយគ្រប់ហើយ [illegible] ពុំខាន ។ ហេតុនេះ ទើបយើងត្រូវតែគ្រាទុកចំពោះពាក្យពោលទាំង និងសំនួរវោហារ ជាដើមប៉ុណ្ណោះ ដើម្បីឲ្យអស់លោកភ្ញាក់ប្រាប់ថា ក្នុងសម័យជាង១០០ឆ្នាំមកហើយ នោះគេការប្រើវិធីនិងសំនួរវោហារសារសព្ទស័ព្ទ ខាងចិនខុសគ្នានឹងសម័យសព្វថ្ងៃនេះបន្តិចបន្តួច ។

នៅវេបផុតនេះ យើងមានសម្ដីថា ព្រះរាជក្រឹត្យ ក្រមហៅហ្វាយស្រុកនេះ ល្មមជាគ្រឿងបញ្ជាក់នូវគោលការ អ្នកប្រាជ្ញបានខ្លះ អំពីរបៀបត្រួតត្រាស្រុកទេស នាសម័យ[illegible] ផែនដីស័ក្តិរបស់ចៅហ្វាយស្រុក

ជាដើម ក្នុងគ្រាកាលព្រះបាទសម្ដេចព្រះជ័យជេដ្ឋាធិបតី (ព្រះអគ្គបទ) ព្រមទាំងការប្រែស័យកាន់គ្នាទៅវិញទៅមក រវាងបណ្ដាក្សត្រ នឹងពួកមន្ត្រី នឹងប្រកែករបស់មនុស្សជាន់នោះមានបែកជាពួកជាក្រុមដូចម្ដេចខ្លះ? បើទុកជាមិនបានហ្មត់ចត់ល្អ ក៏ល្មមឲ្យអស់លោកបានជ្រាបខ្លះៗ ដោយអំពើ ៗ ។ ដោយយ៉ាងហោចទៅ យើងយល់ថា គង់ជាប្រយោជន៍ផលអស់លោក-អ្នក ដែលចង់ជ្រាបចង់ដឹងក្បួនច្បាប់ចាស់ ៗ បានខ្លះជាពុំខាន ។

ពុទ្ធសាសនបណ្ឌិត្យ ថ្ងៃ ៥ សេបតម្ប៊ែ ១៩៤៤

ហ្វិតពន្ធមន្ត្រី ញ៉ុក-ថែម

# ច្បាប់ក្រមចៅហ្វាយស្រុក

សុភមស្តុ ស្វស្តិសិរីសុភមង្គលមហាជយាតិរេក ១៧៤១ ស័ក ជូវ នក្សត្រ ១ កើតមាឃមាស ព្រហស្បតិវារសារនាមន្តិ(១) ផុល (ផុះ) អំពី ព្រះរាជហឫទ័យ នៃសម្តេចព្រះឧទ័យរាជាធិបតី ព្រះស្រីសុរិយោពណ៌ បរមនាថ ព្រះបាទព្រះបរមបពិត្រ បិតជាវង្សត្រកូលត្រៃកម្ពុជាធិបតី សិរីយសោធរ នគរឥន្ទបត្ត កុរុរដ្ឋរាជធានីបុរីរម្យឧត្តមព្រះរាជស្ថាន

---

១ ត្រង់ពាក្យថា "សុភមស្តុ ស្វស្តិសិរីសុភមង្គល មហាជយាតិរេក" ប្រែថា សូមសួស្តីសិរីមង្គល និងជ័យជំនះដ៏ប្រពៃក្រៃលែងកួរមាន. . . ។ "១៧៤១ ស័ក" សំដៅ បកមហាសករាជកន្លងទៅហើយបាន ១៧៤១ ឆ្នាំ ។ "ជូវនក្សត្រ ១ កើតមាឃមាស ព្រហស្បតិវារសារ" គឺឆ្នាំជូវ ឯក្យត្រ ១ កើតខែមាឃ ថ្ងៃព្រហស្បតិ៍ ដ៏រាសីខ្ពឹមសារ ( ប្រកបដោយឫក្សពារពេលាល្អ ) ។ „នាមន្តិ" គឺ ៣ ម៉ោង - គឺ ប្រែថា នាឡិកា មានសេចក្តីថា ប្រាកដជា, ពិតជា, ទៀងទាត់, ដាក់ស្បាន់ ។ តាមទំនងនេះ ទើបសមនឹង សេចក្តីតទៅទៀតថា ផុល (ផុះផុះចេញ) អំពីព្រះរាជហឫទ័យ. . . ។ ១ វិញទៀតពាក្យថា "មន្តិ" នេះយើងបានប្រទះឃើញជាច្រើនអន្លើ ក្នុងសិលាចារឹកនគរវត្ត ដូចឧទាហរណ៍ក្នុងផ្ទាំងសិលាចារឹក លេខ ៤ បន្ទាត់ទី ៤-៥ ថា "សុភមស្តុ ១៤៨៨ ស័កខាលនក្សត្របុរ៉ា ... ថ្ងៃសៅរ៍ ព្រហស្បតិ៍ការ មន្តិអកហ្លួង អភៃយរាជនុអ្នកអរជម្ម័មានចិត្តសទ្ធា. . ." ត្រង់ពាក្យថា "មន្តិ" នេះបានសេចក្តីថា "គឺម" ឬ "ប្រាកដជា" ហ្នឹងឯង ។ ឧទាហរណ៍ ក្នុងសិលាចារឹកលេខ ៦ បន្ទាត់ទី ១៤-១៥ "ចាស់ត្រមស្តុ ១៥២១ ស័ក កុរុអស្សុជ ... ថ្ងៃព្រហស្បតិ៍ការមន្តិ ឧកហ្លួងអភ្ញៃកន. . . " ។ ពាក្យថា "មន្តិ" ក្នុងសិលាចារឹកនេះ ក៏មានសេចក្តីប្រែដូច ខាងលើនេះដែរ ។

ស្ដេចគង់ពុំមានកេរ្ដិ៍ប្រពៃ សន្តកនាមឈ្មោះបន្ទាយកែវ(១) នៅខេត្តប្រសព្វមុខបួន មួយអន្លើនឹងព្រះមហាសង្ឃរាជ គ្រូសមណព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតកវីមន្ត្រីមុខបន្តុស្ដក្រមការ ជាយ.បរិវារសម្រាប់ព្រះបាទអ្នកជាម្ចាស់ ទើបស្ដេចទ្រង់ព្រះចិន្ដា ទ្រង់ព្រះឈ្មោះយល់ពុំទៀវផ្ទះក្រោមកើតភោគផល ព្រះអង្គទៅដកល់ឲ្យបិតបេរិកាលដ៏លើនេះ ពុំឲ្យសៅហ្មងគ្រង់អស់បិទ្ធអាណាប្រជានុរាស្ត្រ តាសកាក្មួយពារផងតាំងឲ្យមាខ្សែឡើយ ទើបព្រះបាទបរមនាថបរមបពិត្រ ស្ដេចបើកព្រះរាជទ្រព្យរាជសារពេះនេះ ។

ត្រាស់ទ្រង់ព្រះបង្គាប់ឲ្យធ្វើ ព្រះបន្ទូលពិសេសដកល់ទុកនៅលើត្បូង អ្នកទៅហៅទ្រព្យ សួស ផ្ដាច់ព្រះរាជការសារពើទាំងពួង ឲ្យបេះស្រមីលើអស់មុខមន្ត្រីធំ–តូចផង ឲ្យបានព្រះរាជការផ្ទះក្រោមសុខក្សេមប្រសើរ ទើបអ្នកទៅហៅទ្រព្យ ទ្រង់ហៅអស់មន្ត្រីធំ–តូចមកជំនុំព្រម ឲ្យខកញ៉ាំមហាទេព (មាស) ព្រះសារស្ដាព្រះបព្យាប់ក្រមទៅហៅយស្រុកអំពីពុកណាយកមកស្រង់បម្ទង់.ឲ្យអស់ទៅហៅយស្រុកយកទៅទុកសម្រាប់ស្រុកទាំង ២ នឹងបានជំងឺបង្រាប់ ដឹងព្រះរាជការ ជំនុំត្រូកស្ដេចទ្រង់ស្រោលដោយទូរប្រការនោះ ។

---

១ បន្ទាយកែវ គឺព្រះរាជវាំងក្រុងភ្នំពេញ ប៉ុន្តែក្នុងសម័យនោះ ប្រហែលជាតាំងនៅខាងជើងវត្តឧណ្ណាលោម មិនមែននៅខាងត្បូងវត្តផ្លូវសម័យសព្វថ្ងៃនេះទេ ។

តាមច្បាប់អំពីបុរាណ ថាបើព្រះមហាក្សត្រទ្រង់ទទួលរាជ្យក្ដីទ្រង់គ្រងរាជ្យក្ដី បើបានទទួលស្រេចហើយ ឲ្យចៅហ្វាយឃ្លាំងប្រាប់ស្មូម មានទៀនទូវស្លាត្រួយទៀនធូបផ្កាភ្ញី នាយណាស្រង់ប្រាប់អប់ទឹក នាយព្រះសំអាងប្រដាប់គ្រឿងគន្ធពិដោរផង ចៅហ្វាយសង្ឃការីនាំទៅថ្វាយបង្គំព្រះ ស្រង់ព្រះពុទ្ធរូបឲ្យគ្រប់ព្រះវិហារផង ពោះខេត្តបាងកបក្ដី នៅលើក្ដី សីនឲ្យគ្រប់អស់តាំងអម្បាលណោះឯង សូមឲ្យមានព្រះជន្មប្រកបនឹងរាជ្យឲ្យយឺនយូរ សូមឲ្យត្រជាក់ត្រជុំ (ផាក់) ព្រះមហាក្សត្រ ទូវអស់មុខមន្ត្រីអាណាប្រជានុរាស្ត្រផង ។

ហើយមុខមន្ត្រី ធ្វើសំបុត្រគប់ចៅហ្វាយ (នាង) ក្នុងប្រែនាយ ពល ពញា ព្រះ នាំបញ្ជាទៅដល់អស់ចៅហ្វាយស្រុកឲ្យបានដឹង ដ្បិតព្រះបាទអម្ចាស់ជាម្ចាស់ឡើងទ្រង់រាជ្យ គ្រងរាជ្យ បើមានអាជ្ញាបញ្ញមថ វិវាទគ្នាកក់វាទកកេកយកទ្រព្យរបស់អស់ក្រស្ដ ឲ្យប្រកោះចាប់ឲ្យខ្ជាប់ ឲ្យនាំចូលមក ឲ្យអស់ពិនុំពិចារណា បើកាត់មែននោះ ឲ្យធ្វើជាយទូវទោសធ្ងន់ស្រាល ល្មមបងចងប្រកឃ្នាងបាញ់កាប់វាគឲ្យកោតខ្លាច កងតាល កុំឲ្យមនុស្សផងការតែង (បំ) ព្រាន់ធ្វើទុក្ខក្រស្ដផង ។ ហើយឯចៅហ្វាយស្រុកទូវអស់គ្នាក់អារស្រុកតាំងអម្បាលណោះ កុំឲ្យធ្វើទុក្ខ បុកបិនបង្ហិនអស់ក្រូវផងតាំងពួង បើចៅហ្វាយស្រុកធ្វើទុក្ខអស់ក្រស្ដ

ហើយ ចៅហ្វាយស្រុក (ក៏) ត្រូវទោសដោយទូវក្ទង់សោលពុំប្រណី ឡើយ ហើយឲ្យចៅហ្វាយស្រុកទូវគស់នាក់ការប្រាប់ប្រាប់អស់កស្រ្ដ ចំណុះស្រុកផងចាំនួនតួន ៗ

ឯណាអ្នកស្រែក៏ឲ្យសង្កាត់ធ្វើស្រែ ឯណាអ្នកចំការឲ្យសង្កាត់ធ្វើ ចំការ ឯណាអ្នកជំនួញ ឲ្យសង្កាត់ខំជួញ ឯណាអ្នកធ្វើការអ្វី ក៏ឲ្យសង្កាត់ ធ្វើការនោះៗ ៗ ឯអ្នកព្រះសង្ឃចៅគួឲ្យសង្កាត់សូត្រមន្តថ្វាយបង្គំព្រះ ផម្រែះអាបត្តិឲ្យសំពះទោសចក្រ សំពះបីលឲ្យរណ្តាប់ព្រះវិហារឲ្យល្អ កុំឲ្យបាក់បែកវែកកបោកឡើយ ឯអ្នកសាមណេរឲ្យកាន់សីល ៧ ថ្ងៃម្តង កុំឲ្យខានឡើយ បើរដូវចូលវស្សា នោះមានទាយកគេនិមន្ត ចូល ឯផ្ទៃ កុំបីឲ្យខានឡើយ នេះហៅផ្គត់ផ្គង់ប្រមែងគន់ព្រះពុទ្ធសាសនា រក្សា ផ្ទៃក្រោមឲ្យចំរើនរុងរឿងកុំឲ្យទុក្ខក្រត្រងផ្ទៃក្រោមឡើយ ឪសុខសិរី សួស្តី នឹងវុឌ្ឍិប្រសើរនឹងចំរើន (ដល់) ព្រះមហាក្សត្រាធិរាជ ដ៏ជាតម្កើងផ្ទៃ ក្រោមហោង ៗ

តាំងពីឯព្រះមហាក្សត្រទ្រង់រាជ្យនោះឲ្យមានរត្នតាំង ៧ ហើយ ឲ្យមានភ្នែកផ្ទៃក្រោម មាត់ផ្ទៃក្រោម ជួនផ្ទៃក្រោម សាច់ផ្ទៃក្រោម ស្បែកផ្ទៃក្រោម ៗ

ឯរត្នតាំង ៧ នោះគឺចៅហ្វា (វល្ល) ១ យមរាជ ១ វាំង ១ ក្រឡា ហោម ១ ចក្រី ១ មហាមន្ត្រី ១ មហាទេព ១ នេះហៅមុខមន្ត្រីជាធំតាំង ៧

(នូវទ្រទ្រូងទាំង ៤)[១] នេះឯងតែងទីនងជម្រង់ព្រះមហាក្សត្រ តែងនឹងក្រាបទូលព្រះមហាក្សត្រអំពីព្រះរាជការផ្ទៃក្រោមយប់ថ្ងៃដោះទុក្ខរាស្ត្រ ។

ឯក្នុងផ្ទៃក្រោមនោះ គឺអ្នកដ៏ចេះហោរដឹងធ្វាយប្តូលាយឲ្យ (ធ្វើ) ជាមន្ត្រី ។

ឯឆ្អឹងផ្ទៃក្រោមនោះ ឲ្យជ្រើសរើសរកអ្នកក្លាហានឲ្យ (ធ្វើ) ជានាហ្មឺន ។

ឯសាច់ផ្ទៃក្រោមមានការជាកម្រៃក្រាយ ឲ្យខំអស់ទ្រព្យសម្បត្តិនោះឯង[២] យកមកផ្គត់ផ្គង់ព្រះរាជការ ។

ឯស្បែកផ្ទៃក្រោមនោះ គឺអស់រាស្ត្រពុំមានទ្រព្យសម្បត្តិអ្វីថ្វាយព្រះមហាក្សត្រ ឲ្យមេត្តាករុណាតែដូចគ្នា ដ្បិតសឹងជាខ្ញុំជាអ្នកស្រុកហោង ។

---

១ មន្ត្រីទ្រទ្រូងទាំង ៤ គឺសំដៅយកចតុស្តម្ភទាំង ៤ និងអធិបតី ១ ទៀតជាតំរប់ ៥ ឬហៅតាមសម័យសព្វថ្ងៃនេះថាក្រសួងសេនាបតីទាំង ៤ ជាតំរប់ ៥ គឺអគ្គមហាសេនាដែលជាអធិបតី ។ ក្នុងទីនេះ មានរៀបរាប់ឈ្មោះរត្នទាំង ៧ ហើយ មិនបាច់រាប់យកទ្រទ្រូងទាំង ៤ មកបញ្ចូលទៀតទេ ព្រោះទ្រទ្រូងទាំង ៤ បានចេញឈ្មោះក្នុងរត្នទាំង ៧ រួចមកហើយនោះឯង ។ តាមធម្មតា ទ្រទ្រូងទាំង ៤ គឺហៅ [illegible] ១ យមរាជ ១ វាំង ១ ក្រឡាហោម ១ ចក្រី ១ បើថែមបញ្ចូលទាំងមហាមន្ត្រីនិងមហាទេព ទាំងពីរនេះទៀតគេហៅថារត្នទាំង ៧ វិញ ។ ហេតុនេះ បានជាត្រង់ពាក្យថា “នូវទ្រទ្រូងទាំង ៤” ទើបយើងបានវង់ក្រចកទុកជាសំគាល់ ។

២ បិហៃលផាសំដៅយក សេដ្ឋីគហបតី ដែលមានទ្រព្យសម្បត្តិច្រើន ព្រោះតាមទំនៀមតាំងដើម ព្រះមហាក្សត្រតែងទ្រង់ជប់លៀង តែងតាំងអ្នកមានទ្រព្យសម្បត្តិច្រើនឲ្យធ្វើជាមន្ត្រីមានសក្តិយសខ្ពង់ខ្ពស់ ដើម្បីប្រគាប់ព្រះកិត្តិយសរបស់ព្រះអង្គ ឬដើម្បីពឹងពាក់ប្រើប្រាស់ក្នុងគ្រាក្រងាយ ទុកជាសាច់របស់ផ្ទៃក្រោម ។

ឯមន្ត្រីជាធំនោះ (គឺ) ចៅហ្វាយអ្នកលេងនូវចម្បាំងស្រាល់អណ្តាប់នោះមកចៅហ្វាយរាំង អណ្តាប់នោះចៅហ្វាយព្រះរាជកេង ទាំង ២ នូវអស់មុខមន្ត្រីទាំង ៧ នោះសុំព្រមចូលអនុកូលនឹងគ្នា ជាដូចបងនឹងប្អូន អា-ពុកម្តាយជាមួយផងគ្នា ។

បើក្អាក់ក្អាឯចម្បាំងស្រាល់ នូវអ្នកលេងនោះ តោះមានព្រះរាជការក្តី កើតកង្វល់ក្តី សុំឲ្យ ហៅនាយពល (ក្រោម) ស្តាប់បង្គាប់មករិះគិត បើព្រះរាជការតូចល្មមរិះគិតថ្វាយបាន នោះទើបរិះគិតកាត់តែង ដោយនូវប្រការនោះ បើរាជការនោះធំ សុំរិះគិតឯងពុំបាន ទើប (ឲ្យ) មន្ត្រីធ្វើសំបុត្រកត់ថ្ងៃឲ្យជូនមន្ត្រីទាំង ៦ ឲ្យ ទៅជុំនុំឯសាលា ហើយមន្ត្រីក្នុងសាលារិះគិតពិចារណា នឹងអស់មន្ត្រីទាំងនោះ ៗ បើរាជការល្មមរិះគិតឯងបាន ទើបរិះគិតកាត់តែង ដោយនូវព្រះរាជការនោះ បើរាជការនោះធំនឹងរិះគិតឯងពុំបានឡើយ ទើបបបួលគ្នាឡើងទៅក្រាបទូល បើសព្វព្រះរាជហឫទ័យហើយ ទើបចុះទៅកាត់តែងដោយនូវប្រការនោះ ៗ

ឯច្បាប់អំពីបុរាណរាជ្យរៀងមក បើនឹងចិញ្ចឹមជាចៅហ្វាយស្រុកធំ-តូច នោះសុំឲ្យចិញ្ចឹមខ្មែរ បើសៀម បើលាវ ទៅចិនកូនចិន កំណើតនៅភាយ បេះភាសា (ខ្មែរ) បេះច្បាប់ខ្មែរ នោះទើបចិញ្ចឹមជាចៅហ្វាយស្រុកបាន ។ អ្នកទេសនឹងចិញ្ចឹម (ឲ្យធ្វើជាចៅហ្វាយស្រុក) ពុំបានឡើយ ឲ្យតអ្នកទេសទាំងអម្បាលណោះមកនៅស្រុកខ្មែរ ពុំដែលធ្វើស្រែឡើយ

ហើយពុំដឹងច្បាប់ខ្មែរ ដឹងប៉ុន្តែជួញ ដ្បិតអ្នកទេសមានតែចិត្តកាច លោភចង់បានតែរបស់ច្រើន ហើយគិតតែជួញ បើជួញហើយចិត្តខិតខំណាស់ឯងទើបបានផាប់ ហើយចិត្តនោះពុំអាស្រូវប្រណីពស្ត្រ ។ បើកំណើតជាមួយទើបប្រណីអាស្រូវគ្នា បើកំណើតដទៃហើយពុំអាស្រូវគ្នាឡើយ ចៅហ្វាយស្រុកអាងតែខ្លួនជាចៅហ្វាយលើគេ ហើយ (អាង) ថាជាធំ ហើយខំឯង[1] បើខិតខំណាស់ហើយ កស្ត្រចំណុះស្រុកពុំស្រណុកចិត្ត ហើយកើតកោលាហលស្អប់ចៅហ្វាយស្រុកនោះ ស្អប់មកដល់អម្ចាស់ផ្ទៃក្រោមជាពុំអាស្រូវ ហើយអម្ចាស់ផ្ទៃក្រោម ខឹងព្រួយព្រះហឫទ័យពុំលែងឡើយ ។

---

១ គឺប្រើអំណាចបង្ខិតបង្ខំរាស្ត្រតក្កតិច ឲ្យរាស្ត្របាំសេចក្តីក្តៅក្រហាយ ដោយសារតែខ្លួនជាចៅហ្វាយស្រុក ។

(មាៈ៩៣)

# ពង្សាវតារប្រទេសចិន

ហ្គូគិនិពន្ធមន្ត្រីញ៉ុក - ថែម រៀបរៀង

(តមក)

ថែមទាំងគេបន្ទោះទុកាសទីងបំផ្លាញចិន ក្នុងកាលដែលចិនថយខ្សោយអំណាច ហេតុនេះបានជាក្នុងពុទ្ធសករាជ ១១៦៧ ពួកតួកគិទិស-ខាងកើតបានលុកលុយចូលមកក្នុងខេត្តដែនចេន-ស៊ី ហើយលើកទ័ពដើរសំដៅក្រុងទៅស្រុកស៊ុ-អាន ៗ ក្នុងវេលានោះ ព្រះបាទលី-យួននៅជាព្រះយោកជាធិកជនៅឡើយ ទ្រង់តក់ស្លុតភិតភ័យជាខ្លាំងខ្លាចពួកតួកគិ ទើបទ្រង់មានព្រះឱង្ការបង្គាប់ឲ្យព្រះរាជឱរសផ្លាស់ទីក្រុងពីស៊ុ-អាន ទៅទីកន្លែងថ្មីទៀតទិសខាងត្បូងជាប់ទន្លេយ៉ាំង-សេ ត្រើយខាងណាយ ៗ ប៉ុន្តែព្រះរាជឱរស លី-ចេមិន មិនយល់ព្រម ទើបទ្រង់ត្រៀមទ័ពចាំទទួលពួកតួកគិ រួចលើកទ័ពចេញទៅដល់តំបន់ប៉ិន-ចៀវ ឆ្នេរទន្លេហ្វាង-ហូ នៅទិសខាងកើតឆៀងខាងជើងស្រុកស៊ុ-អាន ក៏ស្រាប់តែជួបប្រទះនឹងពួកទាហានតួកគិ ដែលមាននាយក ២ នាក់ មេទ័ពមួយឈ្មោះកៀ-លី មេទ័ពម្នាក់ទៀតឈ្មោះតុ-លី ដែលធ្លាប់ជាមិត្រផឹកទឹកសម្បថជាមួយនឹងលី-ចេ-មិនមកពីមុន ៗ នៅវេលានោះពួកទាហានចិនមានសេចក្ដីញៀកដោយមកជួបនឹងខ្មាំងសត្រូវធាប់ពេក - នៅត្រានេះឯង ដែលលី-ចេមិន បានសំដែងសេចក្ដីក្លាហានអង់អាចឲ្យពួកទាហានរបស់ខ្លួនឃើញ និងបង្ហាញដល់ពួកទាហានរបស់ខ្មាំងសត្រូវផង ពោលគឺលី-ចេមិន នាំទាហានមួយរយនាក់ តែចូលទៅក្នុងចំណោមពួកទាហានតួកគិហៅតដល់ខ្លួនមេទ័ពតួកគិ

តាំងពីរនាក់ ហើយងាកទៅចំមុខកៀ-លីជាមុនគេស្រែកថា "ក្រុងចិនមិនមានជំពាក់កែវនពួកតួគីឡើយ ហេតុអ្វីក៏ពួកតួគីលើកទ័ពចូលមកលុកលុយក្រុងចិនដូច្នេះ ណ្ហើយចុះ យើងជាមេទ័ពនឹងមេទ័ពច្បាំងតស៊ូគ្នាក្នុងវេលានេះ ដើម្បីសម្រេចសេចក្ដីថាខាងណាឈ្នះខាងណាចាញ់ យើងមានតែពាហនសេះមកជាមួយត្រឹមម្ភៃរយប៉ុណ្ណោះទេ" ។ កៀ-លីមិនឆ្លើយថាអ្វីឡើយ លី-ចេមិនក៏ងាកទៅរកតុ-លី ហើយពោលថា "លោកបានបង់មេត្រីនឹងយើងរួចមកហើយ នៅវេលាដែលលោកកំពុងមានគ្រោះថ្នាក់ យើងក៏បានជួយស្រោចស្រង់ដោះស្រឡះ ចុះឥឡូវនេះលោកក្បត់ពាក្យប្រតិជ្ញាដែលបានផឹកទឹកសម្បថជាមួយគ្នាចំពោះមុខទេវតានោះហើយឬ បើដូច្នេះយើងច្បាំងតស៊ូគ្នាតែពីរនាក់ចុះ" ។ លុះលី-ចេមិននិយាយចប់ដោយសព្វគ្រប់ហើយ តុ-លីក៏ឱនក្បាលគំនាប់ហើយបង្គាប់ពាហនរបស់ខ្លួនមិនឲ្យច្បាំង រួចនៅសល់តែកៀ-លីម្នាក់ឯងគ្មានអ្នកណាជួយ ហើយកៀ-លីក៏ដាច់ចិត្តលែងច្បាំង ហើយចាត់បម្រើឲ្យទៅក្រាប់លី-ចេមិនថា សូមជាមិត្រមេត្រី ហើយលែងគិតមកច្បាំងតទៅទៀត ។ តមកពីរបីថ្ងៃ កងទ័ពពួកតួគីក៏ថយត្រឡប់ទៅវិញទាំងអស់ ។ លី-ចេមិនក៏អញ្ជើញតុ-លីឲ្យចូលមកនៅជាមួយផង ហើយថែទាំចិញ្ចឹមរក្សាយ៉ាងបរិបូណ៌ជាសុខសាន្ត ដូច្នេះទើបឃើញថា សេចក្ដីក្លាហានអង់អាចរបស់ព្រះបុរសម្នាក់នេះបានជួយស្រុកចិនឲ្យផុត

ពីអន្តរាយ ហើយឲ្យខ្មាំងសត្រូវថយទ័ពត្រឡប់ទៅវិញបានផង មិនឲ្យមានឈាមមនុស្សធ្លាក់ដល់ដីមួយដំណក់ឡើយ ។

អន្តរាយរបស់ស្រុកចិនដែលកើតមកពីពួកគួកិនោះ មិនទាន់បានផុតផុតស្រឡះនៅឡើយ ទើបកៀ-លីដែលព្រមធ្វើជាមិត្តនឹងលី-ចេមិនហើយនោះ តែក្រោយមកដោយលី-ចេមិនមិនទទួលចិញ្ចឹមផប់លៀង ក៏ត្រឡប់តាំងខ្លួនជាសត្រូវឡើងវិញទៀត លុះក្នុងឆ្នាំពុទ្ធសករាជ ១១៦៩ កងទ័ពគួកិក៏រុកលុកលុយចូលមកខាងកាន-ស៊ូ មានកំឡាំងទាហាននេះដល់ទៅមួយសែន វាយកងទ័ពចិនបែកទៅតឹង-យ៉ាង ហើយលុកចូលរៀងៗ មកដល់ខេត្តវ៉ៃ-ហ្វូ រហូតដល់ទ្វារនគរស៊ី-អាន លី-ចេមិន (ដែលបានឡើងគ្រងរាជ្យ ជាព្រះបាទថៃ-សុងមហារាជហើយ) ទ្រង់យល់ឃើញច្បាស់ថា ប្រសិនបើមិនវាយទ័ពពួកគួកិឲ្យបែកខ្ទេចខ្ទីទៅនៅក្នុងគ្រានេះទេ ប្រទេសចិនច្បាស់ជានឹងធ្លាក់នៅក្នុងអន្តរាយជាពិតប្រាកដមិនខាន ។ ពួកទីប្រឹក្សារបស់ព្រះអង្គនាំគ្នាណែនាំឲ្យព្រះអង្គប្រថាប់នៅក្នុងស៊ី-អាន តែទ្រង់មិនយល់ព្រម ដោយទ្រង់គិតថា បើទ្រង់នៅចាំទទួលទ័ពគួកិនៅស៊ី-អានហើយ មុខជាទ័ពគួកិបំផ្លាញស្រុកផ្សេងៗ នៅខាងក្រៅឲ្យអន្តរាយអស់ទៅមិនខាន ហេតុនេះ វិធីដែលល្អបំផុត ត្រូវចេញទៅច្បាំងតបនឹងកងទ័ពគួកិក្នុងវេលានេះឯង ។ ទើបស្ដេចចេញពីស៊ី-អាន សំដៅត្រង់ទៅខាងខេត្តវ៉ៃ-ហ្វូតែម្ដង ហើយ

ស្តេចបានទៅដល់បន្ទាយពួកគួកិមុនកងទ័ពព្រះអង្គទៅដល់ ហើយមានព្រះបន្ទូលថា "ពួកគួកិធ្វើខុសនឹងស្ថានៈមិត្រធំណាស់" ។ ឯពួកទាហានគួកិគ្រាន់តែក្រឡេកឃើញ ព្រះបាទថៃ-សុងមហាពជក្លាម ក៏មានសេចក្តីភិតភ័យតក់ស្លុត នាំគ្នាចុះពីខ្នងសេះមកថ្វាយបង្គំដោយសេចក្តីគោរព កងខណៈនោះឯង កងទ័ពរបស់ព្រះអង្គក៏បានទៅដល់ព្រមគ្នា កងទ័ពទាំងសងខាងក៏ប្រុងប្រៀបចាំតែវៀនខ្លួន ។ ព្រះបាទថៃ-សុង មានបន្ទូលឲ្យកងទ័ពរបស់ព្រះអង្គត្រៀមនៅទីកន្លែងសិន ហើយព្រះអង្គស្តេចជិះសេះ បរកាត់កងទាហានគួកិចូលទៅមួយព្រះអង្គ ដើម្បីទៅជួបនឹងមេទ័ពគៀ-លី នៅវេលានោះមានហេតុចម្លែកមិនប្រាកដ គៀ-លីគ្រាន់តែក្រឡេកឃើញព្រះបាទថៃ-សុង ក៏លែងគិតខឹងធ្វើចម្បាំង ពួកមេទ័ពខាងពួកគួកិក៏អស់សេចក្តីមានៈក្លាហានខឹងច្បាំង កងទ័ពយ៉ាងធំសំបើមរបស់គួកិ ក៏ចុះចាញ់ព្រះបាទថៃ-សុងមហាពជជាគំរប់ទី ២ ដោយប្រទេសចិនមិនមានខូចខាតសាច់ឈាមឬកំលាំងណាតែមួយឡើយ ។

កាលបើមានសត្រូវក្រុកលុកលុយមក មានសេចក្តីអន្តរាយដល់ស្រុកចិនដូច្នេះទៀត ទើបពួកក្រុមទីប្រឹក្សារបស់ព្រះបាទថៃ-សុងមហា-ពជ នាំគ្នាក្រាបទូលពន្យល់សុំឲ្យទ្រង់ជួសជុលកំផែងធំ ដែលបាក់បែកទៅជាច្រើនហើយនោះ ឲ្យបានគង់វង្សមាំមួនឡើងវិញ ប៉ុន្តែ

យោបល់នេះ ព្រះបាទថៃ-សុនទ្រង់បដិសេធ ហើយទ្រង់មានព្រះបន្ទូលថា ស្រុកចិនដែលប្រាសចាកអន្តរាយបានសេចក្តីសុខសប្បាយនោះមិនមែននៅនឹងកំផែងធំក្រាស់នោះទេ ស្រេចនៅលើមានមនុស្សខ្លាំងពូកែទេតើ ។ នៅគ្រានេះ ព្រះបាទថៃ-សុន មហារាជ ទ្រង់តាំងព្រះទ័យយ៉ាងដាច់ស្រេចថា នឹងបង្ក្រាបប្រាមពួកតួកិឲ្យទាល់តែបាន ហើយការបង្ក្រាបប្រាមនោះគាត់ធ្វើដោយកំឡាំងប្រាជ្ញាច្រើនជាងកំឡាំងអាវុធ ហេតុនេះ ទើបទ្រង់ព្យាយាមជាវេលា ៤ ឆ្នាំ ក្នុងការញុះញង់ឲ្យពួកមនុស្សនៅក្រោមត្រួតត្រារបស់ពួកតួកិ កើតទាស់ទែងខ្វែងគំនិតគ្នាបែកគ្នាជាអាណាចក្រតូច ៗ ដូចកាលសម័យពីមុន នៅវេលាដែលពួកតួកិមិនទាន់ចូលមកត្រួតត្រា ទើបទ្រង់ចាត់ពួកចារបុរសឲ្យចូលទៅស៊ើបនិងញុះញង់នៅគ្រប់ទីតំបន់ទូទៅ កុសលោបាយបែបនេះមានប្រយោជន៍ជាច្រើន នាំឲ្យដែនដីនៅតំបន់អស់នោះបែកខ្ញែកពីគ្នា ហើយនាំគ្នាមកនៅក្រោមព្រះបរមតេជានុភាពនៃព្រះចៅក្រុងចិនបន្តិចម្តង ៗ ក្រៅពីនេះបានញុះញង់ពួកតួកិទិសខាងកើត ឲ្យលើកទៅច្បាំងនឹងពួកតួកិទិសខាងលិច គឺជាប្រើឧបាយឲ្យសត្រូវច្បាំងនឹងសត្រូវគ្នាឯងជាវិធីដែលព្រះបាទថៃ-សុនយកតម្រាប់តាមមេទ័ពម៉ុង-ទៅ ។

ការដែលអាណាចក្ររបស់ពួកតួកិ បែកខ្ញែកចេញទៅជាខណ្ឌតូច ៗ ដូច្នេះហើយ ក៏នៅតែមិនទាន់ធ្វើឲ្យពួកតួកិបាត់បង់ទន្ទ្រានប្រទេសចិន

ទៅឡើយ ។ មេទ័ពដែលលើកមកប្រមូលសក់យចិនក្នុងគ្រានេះគឺ កៀ-លី ដែលចេញកាតព្រមទទួលចុះចាញ់ព្រះបាទថៃ - សុងមកហើយដល់ ២ គ្រា តែបែរជាលើកទ័ពចូលមកលុកលុយស្រុកចិនទៀត ក្នុងពុទ្ធសករាជ ១១៧៣ វេលាគ្រានេះជាគ្រាដែលព្រះបាទថៃ-សុង ច្បាំងតស៊ូនឹងកៀ-លី ទៀតលំតែបាក់បែកទើបជាការដាច់ស្រេច កៀ-លីចុះនលើកទ័ពចូលមកគាំងនៅប្រទល់ដែនខេត្តតាន់-ស៊ី ។ មានមេទ័ពចិនម្នាក់ឈ្មោះលី-ស៊ុង លើកទ័ពសេះចំនួន ៣០០០ ចូលទៅវាយកាត់ទ័ពតួក ពួកទ័ពតួកក៏ដាច់ចេញជា ២ កំណាត់ ហើយមានទាហានចិនមួយកងទៀត លើកទៅស្កាត់វាយពីក្រោយខ្នង កៀ-លីត្រូវទ័ពចិនវាយតាមដោយមិនដឹងខ្លួនដូច្នេះក៏ដកថយទ័ពត្រឡប់ទៅម៉ុងលី ពួកទាហានចិនក៏ដេញតាមទៅ ទើបមានចម្បាំងយ៉ាងធំឡើងនៅក្នុងដែនម៉ុង-លី រវាងពួកទ័ពកៀ-លីនឹងលី-ស៊ុង នៅទីបំផុតកងទ័ពពួកតួកក៏វិនាសអស់ទៅ ពួកទាហានតួកត្រូវកាប់សម្លាប់ចង់ទៅជាងហ្មឺន ហើយត្រូវចាប់ធ្វើជាឈ្លើយជាងសែន រួមទាំងប្រុស - ស្រី - ក្មេង - ចាស់ រហូតដល់កូនខ្ចីក្នុងស្រឹង ។ ចំណែកខាងកៀ-លី ក្នុងយប់ដែលចាញ់ទ័ពរបស់ខ្លួនបាក់បែកទៅក្នុងដែនម៉ុងលីនោះ ក៏ឡើងជិះសេះបំដាយរត់ទៅតែម្នាក់ឯង ហើយត្រូវពួកទាហានរបស់ខ្លួនចាប់ខ្លួនបញ្ជូនទៅឲ្យចិន ហើយត្រូវដាក់ច្រវាក់រណាងរណោងបញ្ជូនមកស្រុក ស៊ុ-ង៉ាន ។

តាំងអំពីនោះមក ទេវតាដែលមុំផលិភាគខាងកើតនិងភាគកណ្ដាល ក៏ធ្លាក់ទៅជាចំណុះចិន ដោយមានឧកញ៉ាអាមាត្យរបស់ព្រះចៅក្រុងចិន ត្រួតត្រាគ្រប់គ្រង ។ ពួកក្សត្រតូចក៏ក្លាយជាក្សត្រចំណុះ ពួកអ្នកមានពូជអំបូរ ក៏ធ្លាក់ខ្លួនទៅជាខ្ញុំកំដររបស់ចិនអស់ទៅ ។

(មានត)

# នារាយណ៍ទសាវតារ

ឧកញ៉ាទេពពិទូរ ក្រ.សម រៀបរៀង

(តមក)

ទោះបីជាព្រាហ្មណ៍ក៏ពិត តែជាអ្នកអន់ខាងក្នុងការរណរង្គ ជាអ្នកខ្ជាប់ខ្ជួនទៅក្នុងសត្យធម៌ តាំងចិត្តបំពេញបុណ្យកុសលជាដរាប តាំងពីមួយយាទាំងកុមារទាំងតាបសនាំគ្នាចូលព្រៃ ដើម្បីបេះផលាផល នាងតាប-សិនីនៅតាស្រម ក្រោយដែលបោសព្រាស់ហើយ ក៏បានចុះទៅកាន់កំពង់ទឹក ប្រទះនឹងព្រះបាទចិត្ររថ ក្សត្រនគរម្ពុគការតែមានរូបឆោមល្អផូរផង កំពុងតែប្រឡែងលេងនឹងព្រះជាយា ៗ រេណុកានឹកតូចចិត្តថា ព្រោះខ្លួនមកបានជាភរិយាឫសី ទើបមិនបានសេចក្ដីសុខសម្រាន្តដូចគេ លុះងូតទឹកស្រេចហើយក៏ត្រឡប់មកផ្ទះនៅក្រោមកុដិ, ឫសីត្រឡប់មកឃើញនាងកើតទុក្ខមុខស្រពោន ទើបចាប់ឈានមើលដឹងរឿងរ៉ាវនោះហើយក៏ក្រោធ កាលសុមណាវ័តបុត្រច្បងត្រឡប់មក ក៏និយាយប្រាប់តាមដំណើរ ហើយបង្គាប់ឲ្យបុត្រនោះសម្លាប់ម្ដាយចេញ សុមណាវ័តគិតដល់គុណមាតាមិនអាចនឹងសម្លាប់បាន ឫសីបិតាក៏ដាក់បណ្ដាសាឲ្យវិកលចរិត, បុត្រទី ២ – ៣ – ៤ មិនហ៊ានសម្លាប់ដែរ ក៏ត្រូវឫសីដាក់បណ្ដាសាដូចគ្នា ៗ លុះបរសុរាមត្រឡប់មក ឃើញថាមាតាធ្វើខុស ជាហេតុឲ្យថយថោកកិត្តិយសកិត្តិស័ក្ដិ ក៏ស៊ូសម្លាប់មាតា, ជមទគ្និមានចិត្តអំណរប្រែន

ហើយអនុញ្ញាតឲ្យបរសុរាមសូមពរ ៣ ប្រការតាមដែលកុមារត្រូវការដូច្នេះ

១ - សុំឲ្យមាតាត្រឡប់រស់ឡើងដោយប្រាសចាកមន្ទិល

២ - សុំឲ្យបងៗ បាត់វិកលចរិតទាំងអស់គ្នា

៣ - សុំឲ្យខ្លួនមានអាយុយឺន និងអាចតស៊ូសត្រូវតែមានជ័យជំនះជាដរាប ។

រឿងរ៉ាវបរសុរាមប្រាកដមកក្នុងគម្ពីរគណ្ឋក្នុងរឿងរាមាយណៈ (រាមកេរ្តិ៍) សាហេតុដែលកើតតក់ក្ដៅនឹងជាតិក្សត្រនោះគឺព្រះអរជុន កត្តវីរ្យៈ មហាកដនៃនគរខេហិសមតិ ដែលបានព្យាយាមបំពេញវត្តប្រតិបត្តិព្រះទត្តាត្រេយ ចាល់តែជាទីប្រោសប្រាណតិតទីងប្រទានពរឲ្យ ព្រះអរជុនសូមពរ ៧ ប្រការ គឺ ១- មានដៃមួយពាន់ហើយសុទ្ធតែមានឫទ្ធិគ្រប់ៗដៃ, ២- បានថេលុអាចទៅណាទៅបានតាមត្រូវការ, ៣- មានអំណាចបង្ក្រាបពួកខ្មាំងបានដោយសេចក្ដីយុត្តិធម៌, ៤- ឈ្នះរាបលើមនុស្សទាំងអស់, ៥- មានចិត្តជិនខុសដឹងត្រូវអាក្រក់ល្អ, ៦- កុំឲ្យចាញ់អរិពជពៅរី, ៧- ឲ្យអស់ជីវិតដោយព្រះជាម្ចាស់ (ព្រះវិស្ណុ) ជន្មកិត្តិស័ព្ទគឺកកង ។ តាំងអំពីនោះមកព្រះអរជុនក៏មានមហិទ្ធានុភាពល្បីខ្ចរខ្ចាយឡើងរាល់ថ្ងៃ ។

ក្រុងរាពណាសូរ អួចគ្រប់គ្រងនគរលង្កាប្រាថ្នាចង់ណាំងថា ព្រះអរជុនមានឫទ្ធិខ្លាំងណាស់ ក៏គិតចង់ប្រឡងថាដៃមើល ត្រាស់ឲ្យរៀបចំទ័ពទៅវាយពីក្រុងមហិសមតី តែវេលានោះព្រះអរជុនបានស្ដេចទៅ

ប្រពាតព្រៃ បានលើកទ័ពតាមទៅដល់ធ្នូរនមទា ឈប់តាំងទ័ពជិតបូជា ព្រះឥសូរ ព្រះអរជុនក៏ពុនស្រង់ទឹកជាមួយព្រះមហេសីទាំងស្រីស្នំយ៉ាងសប្បាយ បានយកព្រះហស្តកំផ្ទឹកៗ ក៏ហាលឡើងលិចកេនពិធីរបស់ក្រុងពពណ៌ៗ ក៏ក្រោធរុមគ្គិទេះកប្ប ទើបលើកទ័ពទៅព័ទ្ធបក្ចាយព្រះអរជុនៗ រត់ឡើងអំពីទឹក គ្រវែតទានិយាយថាៈងសុំតស៊ូតតួ ក្នុងទីបំផុតព្រះបាទវៃ ១ ពាន់ (អរជុន) បានចាប់ព្រះបាទឥក្រាលផប់ (ពពណ៌) ចងភ្ជាប់ពីក្រោយរថហើយឲ្យលើកទ័ពត្រឡប់ទៅព្រះនគរ បានយកក្រុងពពណ៌ទៅចងផ្កាលនៅកណ្តាលក្រុង គិតទីងធ្វើគត់បង់ តែដំណឹងនេះបានជ្រាបទៅដល់ព្រះបុរីនារទៈៗ ក៏និមន្តទៅទូលព្រះបាទចៅលស្ស្យៈ ហើយនាំគ្នាមកសូមជីវិតទុក ព្រះអរជុនទទឹងក្រុងពពណ៌ត្រឡប់ជាទីងគ្នាហើយសុំធ្វើជាបងប្អូនគ្នាតទៅ ។

តាំងតែពីបានឈ្នះក្រុងពពណ៌មក ព្រះអរជុនក៏រឹតតែល្បីថ្មីដៃខ្លាំងឡើង តែកាលនោះព្រាហ្មណ៍ទាំងក្សត្រកើតច្បាំងគ្នា ព្រះសហស្ស-ពាហុ ក៏ចូលខាងក្សត្រ ពួកព្រាហ្មណ៍ញញើតដៃមិនសូវកើនតស៊ូ ។ ព្រះអរជុននេះមានសេចក្តីគុំគួនស្អប់ពួកព្រាហ្មណ៍ណាស់ គ្រាមួយនោះក្រោធនឹងព្រះវសិដ្ឋមុនី ទើបលើកទ័ពទៅចូលអាស្រមព្រះមុនីៗ ក៏ប្រើគោកាមធេនុ() ; ទៅកេតពលមកច្បាំងនឹងព្រះអរជុនបែកខ្ចាត់ខ្ចាយទៅ

១ គោ.នេះអ្នកម្ចាស់ប្រាថ្នាអ្វីៗ ក៏រកឲ្យបានដូចចិត្ត ។

ព្រះវសិដ្ឋនាំពួកឫសីជីព្រាហ្មណ៍ទៅគាល់ព្រះឥសូរទូលប្ដឹងថា ព្រះអរជុន ដេញរុករានព្រាហ្មណ៍ ព្រះសិវមានទេវឱង្ការឲ្យព្រះវិស្សុកម្មមកកើតក្នុង គភ៌នាងរេណុកា (គឺកើតជាបរសុរាម) ដើម្បីប្រាបព្រះអរជុន ។

នាថ្ងៃមួយព្រះអរជុនទៅប្រពាតព្រៃបាញ់សត្វ មានសេចក្ដីនឿយហត់ ក៏ចូលមកសម្រាកនៅអាស្រមព្រះឫសីជមទគ្និ បិននៅ នាងរេណុកាបានធ្វើជំសណ្ការៈកក់តាក់ទទួលពេញទី នាងហៅគោកាមធេនុឲ្យនាំយកអាហារមកថ្វាយ, ព្រះអរជុនឃើញគោបំប៉ុន ទើបអង្វរសុំដោយល្អ នាងមិនព្រមឲ្យដោយហេតុផលថាមិនគួរមកដណ្ដើមអ្នកទាល់ក្រ ព្រះអរជុនសុំកូនគោ នាងក៏មិនព្រមឲ្យទៀត ព្រះអរជុនទើបខឹងក៏ដឹកកូនគោយកទៅព្រះឌីយ ថែមទាំងឲ្យពួកពលរំលំដើមឈើជុំវិញអាស្រមរលំអស់ ព្រះឫសីប្ដីត្រឡប់មកក៏មិនបានសំដែងការខឹងក្រោធ គ្រាន់តែប្រាប់នាងថា ដល់វេលាគ្រោះថ្នាក់ហើយទឹងទៀសកាន់ជួបម្ដេចក៏មិនរួច សុំឲ្យនាងបំពេញសមាធិតទៅ កុំឲ្យអំពល់គិតទឹកដល់ឡើយ ។

បរសុរាមត្រឡប់មកឃើញក៏ក្រោធ កន្ត្រាក់បានពូថៅទឹងជទ្ធូជីវិតស្ទុះតាមទៅទាន់ព្រះអរជុនពាក់កណ្ដាលផ្លូវ ។ បានច្បាំងតស៊ូគ្នាតតួយ៉ាងពេញទំហឹងដោយសព្វខ្លួន ព្រះអរជុនបង្គាប់ឲ្យពួកព្រាហ្មណ៍ចូលពោមពាប់ ក៏ត្រូវបរសុរាមសម្លាប់ខ្ទប់កប់មិនអស់ បរសុរាមយឹតធ្នូបាញ់ទៅត្រូវដៃព្រះអរជុនដាច់ជ្រុះអស់ទាំងមួយពាន់ ហើយលោកចូល

ទៅកាត់ព្រះសិរក្សត្រអរជុនហើយក្តួចផ្ដាច់ទៅទៀត ។ ព្រះអរជុនជាអ្នកល្បីល្បាញឥទ្ធិឫទ្ធិ ១ ដូចពោលមកហើយ ការដែលបរសុរាមបង្ក្រាបបានមានជ័យជំនះលើព្រះអរជុនដូច្នេះ សេចក្ដីល្បីល្បាញទាំងប៉ុន្មានក៏ធ្លាក់មកលើបរសុរាមវិញ, ម្ដងនេះជាហេតុឲ្យទោសរបស់ព្រះអរជុនគិតព្យាបាទបរសុរាម ១ លើកទៅទៀត, កាលស្រេចកិច្ចសពព្រះបិតាហើយ ក៏ចណ្ណូររហ័ពលលើកទៅឯអាស្រមថ្មី បានលបចូលទៅសម្លាប់ព្រះជមទគ្និជាការសងសឹក, វេលានោះបរសុរាមមិននៅ លុះត្រឡប់មកដឹងហេតុនោះក៏ក្រោធប្ដេជ្ញាចងគំនុំថា នឹងតាំងខ្លួនជាសត្រូវនឹងជាតិក្សត្រទៅ ប្រទះនៅទីណានឹងសម្លាប់ឲ្យអស់កុំឲ្យមានសល់ (ក្នុងទីខ្លះថាសម្លាប់ក្សត្រក្នុងលោកទាំងអស់ ២១ ដងទើបបាត់ខឹង) ក្រោយដែលធ្វើឈាបនកិច្ចសពបិតា ក៏ហោះមកក្រុងមហិស្មតី និយាយឲ្យដេញពួកក្សត្រឲ្យចេញមកច្បាំង, តាមសម្លាប់ក្សត្រអស់ទាំងលោកដល់ទៅ ៧ ដង ឃើញថាក្សត្រប្រុស ៗ អស់ហើយក៏សោយក្រោធ, សល់នៅតែនាងក្សត្របរសុរាមបានសុំឲ្យព្រាហ្មណ៍ជួយបណ្ដុះពូជក្សត្រតទៅ បានលើកយកលោកឲ្យជាទក្ខិណាដល់ព្រះកស្សបមុនី ខ្លួនក៏ទៅនៅឯភ្នំមហេន្ទ្របពិត ។

ក្នុងទីនេះគួរឲ្យសង្កេតថា តាមប្រវេណីព្រះនារាយណ៍ តែធ្វើកិច្ចស្រេចហើយរមែងត្រឡប់ទៅកាន់វៃកុណ្ឋវិញ នេះជាគ្រាដំបូងដែលគេប្រទះរឿងព្រះនារាយណ៍បែងភាគមកធ្វើកិច្ចស្រេចហើយ នៅមិនទាន់

ត្រឡប់ទៅវៃកុណ្ឋវិញ នេះប្រហែលជាដោយហេតុបានពរអំពីព្រះជមទគ្និជាបិតាថាឲ្យមានអាយុវែងស្ថិតនៅរហូតកប្បទើបមានជីវិតមកដល់សម័យអវតារគ្រាទី ៧-៨ មក ក្នុងសម័យនេះមិនត្រូវមុខងារខ្លួនទីនៈពួការក្រោមលោកហើយ ទើបមិនទាន់ត្រឡប់ទៅវៃកុណ្ឋ ៗ តាមរឿងដើមជាកាលណាក្សត្រអស់តាំងផម្លូវថយហើយ ក៏ទៅនៅឯមហេន្ទ្របព៌ត ក៏ចប់អស់រឿងគ្រាទី ៦ តែប៉ុណ្ណោះ តែក្នុងរាមាយណៈសំដែងតំណាលគ្រាទី ៧, និងក្នុងមហាភារតសំដែងតំណាលគ្រាទី ៨ នោះ មានពោលដល់បរសុរាមៈទៀត ៗ ក្នុងរាមាយណៈថា បរសុរាមបបួលរាមចន្ទ (គឺព្រះរាម) ច្បាំងលយុទ្ធគ្នា តែចាញ់ព្រះរាម ហើយព្រមទទួលថាព្រះរាមជាព្រះនារាយណ៍អវតារ នេះជាគួយ៉ាងសឹងមានតែ ១ នេះដែលគេប្រទះព្រះនារាយណ៍អវតារ និងព្រះនារាយណ៍អវតារមកជួបគ្នាហើយ ព្រះនារាយណ៍អវតារចាស់ ព្រមចុះចាញ់ព្រះនារាយណ៍អវតារថ្មី ហាក់ដូចជាការអវតារនោះពេះលាចេញបាន សឹងមិនដែលមានអ្នកណាធ្លាប់គិតឡើយ ៗ ក្នុងមហាភារតៈនិងគម្ពីរបុរាណខ្លះ ដែលគេតែងឡើងសំរាប់សំដែងប្រវត្តិនិងសរសើរព្រះក្ឫស្នាវតារមានពោលដល់បរសុរាមថា គ្រាន់តែជាព្រាហ្មណ៍អ្នកជំនាញក្នុងយុទ្ធសាស្ត្រ ហើយថាជាមិត្តរបស់ព្រះក្ឫស្ណៈប៉ុណ្ណោះមិនបានថាជានារាយណ៍អវតារទេ គេទើបអាចពោលបានថាក្នុងគ្រាទី ៨ នោះបរសុរាមជា "អវតារក្រៅដំណែង" ដោយពិត ៗ

តាមសេចក្ដីដែលអ្នកប្រាជ្ញទាំងឡាយបានពិនិត្យរឿងពីក្នុងគម្ពីរសៃយសាស្ត្រផ្សេងៗ បានសម្រេចសេចក្ដីយល់ថា រឿងបរសុរាមារការដែលពិតនោះក្នុងជាន់ដើមគង់បប់ត្រឹមសម្រាប់ពួកក្សត្រ ដើម្បីសងសឹកជំនួសបិតាប៉ុណ្ណោះ, ឯរឿងដែលតមក គង់ជាតែងតឡើងជាខាងក្រោយដោយអ្នកតែងប្រាថ្នាទីងលើកកិត្តិគុណ នូវបារមីនៃព្រះរាមចន្ទ្រាវតារនឹងព្រះក្រឹស្ណាវតារឲ្យធំវិសេសឡើងជាទីតាំង ៗ

ក្នុងរឿងដែលខេរយើងតែងឡើងសម្រាប់លេងល្ខោនថា បរសុរាម (ដែលគេហៅថារាមសូរ) ជាយក្ស ហើយថាអរជុន (ដែលហៅក្លាយជាអរជុន) ជាទេវតា, សេចក្ដីពិតជាមនុស្សទាំងគូ, បរសុរាមជាតិជាព្រាហ្មណ៍ ។ដែលយល់ថាយក្សប្រហែលជាក្លាយមកពីពាក្យសេចក្ដីក្នុងនាមរបស់បរសុរាម ១ យ៉ាងទៀត គឺ: "ខ្មែក្ស" ប្រែថា "ចោរបាប" ព្រោះប្រតិបត្តិមិនស្មើតាមក្បួនធម៌របស់ព្រាហ្មណ៍ ទាំងជាអ្នកមានទោសខ្លាំង មានចិត្តកាចឃោរឃៅហាក់ដូចជាយក្ស ទើបនាំឲ្យយល់ថា យក្សទាំងសៀមក៏យល់ដូច្នេះដែរ ៗ

រាមចន្ទ្រាវតារ ទីងដំណើរសេចក្ដីក្នុងរឿងរាមចន្ទ្រាវតារៈតទៅ ៗ ក្នុងគម្ពីររាមាយណៈ មានសេចក្ដីថា មាននគរមួយឈ្មោះអយោធ្យាតាំងនៅឆ្នេរទន្លេសរយុក្នុងដែនកោសល ព្រះនគរនេះសម្បូណ៌ដោយទ្រព្យសម្បត្តិព្រះមនូវវិសេសតែងជាធុរសព្រះសុរិយាទិត្យ បានសាងឡើង

សម្រាប់ជាទីស្នាក់នៅនៃក្សត្រសុរិយវង្ស ព្រះបាទឥក្ខាកុ ជាបឋមក្សត្រសុរិយវង្ស មានក្សត្រដំណសន្តតិវង្សចុះមកដល់ព្រះបាទទសរថ ក្សត្រអង្គនេះមានព្រះមហេសី ៣ អង្គ គឺនាងកៅសល្យា សុមិត្រា, និងកៃកេយី, តែគ្មានព្រះរាជបុត្រសេដំណសន្តតិវង្ស ទើបគិតធ្វើពិធីអស្វមេធដើម្បីសូមបុត្រ លុះបានឫក្សល្អក៏អញ្ជើញព្រាហ្មណ៍ ឫស្យស្រិង្គមកជួយធ្វើពិធី ការធ្វើពិធីនោះមានព្រះវសិដ្ឋ (បុរោហិត) ព្រះកមទេពមុនី (ភូឈួយបុរោហិត) ព្រះសុយញ្ញមុនី ។ល។ ជាអ្នកធ្វើ ទាំងពិធីនៅឆ្នេរសរយូនទី, បានអញ្ជើញស្តេចជិតខាង មកជួយជាច្រើន ដូចយ៉ាងព្រះបាទជនក (សុរិយវង្ស) អ្នកគ្រប់គ្រងនគរមិថិលា ក្នុងវិទេហរដ្ឋ ព្រះរាជានគរពារាណសីក្នុងកាសីរដ្ឋ, ព្រះបាទទសរថលែងសេះឲ្យបការទៅគ្រប់ ១ ឆ្នាំ ក៏ត្រឡប់មកវិញ កាលបានឫក្សល្អនាងកៅសល្យាចូលកេងពិធីសម្លាប់សេះ ហើយគង់នៅទីនោះមួយរាត្រី ព្រះរាជទេពីពីរទៀតគ្រាន់តែមកជួយចាប់កាន់សេះដែលគេសម្លាប់ ហើយព្រាហ្មណ៍ពន្លះយកគ្រឿងក្នុងដុត នៅមានដុតសេះដទៃទៀត ៣០០ ព្រះឫស្យស្រិង្គប្រកាសសុំទានឲ្យព្រះបាទទសរថ បណ្តាទេពធិតានូវអ្នកសិទ្ធិវិជ្ជាធរមកប្រជុំ មានសេចក្តីឃើញព្រមគ្នាថា ដល់សម័យគួរនឹងលានទសកណ្ឋ ដែលមានសេចក្តីកម្រើកចិត្តដើរបៀតបៀនឫសីដ៏ព្រាហ្មណ៍ទាំងឡាយ ព្រះព្រហ្មណ៍ទើបអញ្ជើញព្រះវិស្ណុឲ្យអវតារមកកម្រាប គឺបែងកាយមកជា ៤ ចំណែកចូល

បដិស័ន្ធិក្នុងគភ៌ មហេសីព្រះបាទទសរថក្នុងខណៈកំពុងធ្វើពិធី អស្វ-
យុគ ទេវៀនមកអំពីគំនរភ្លើងកាន់ភាជនៈមាសដែលដាក់បាយាសទិព្វច្រុះបំ
ផុះ ព្រះព្រហ្មត្រាស់ឲ្យនាំមកថ្វាយព្រះមហេសីសោយ ក៏ទ្រង់បាន
ទ្រង់មានបុត្រសមដូចប្រាថ្នា ពួកទេវតាចង់ជួយធ្វើសង្គ្រាមក្រាប
អសុរវៃវ ក៏ច្បុតមកកើតជាពានរជាច្រើន ។ (មានត)

# អធិប្បាយសុភាសិតខ្មែរ

## យុនឧត្តមប្រីជា ហប-ពិន

រៀបរៀង (តមក)

### ៧៣- ដេញប្រដាប់, ចាប់ប្រកីដ

ពាក្យនេះជាពាក្យពោលដោះស្រាយ

ចំពោះការងារផងទាំងឡាយ ដែលក្លាយជាកលាកុតាំងពុំគ្មាន ។
ដូចការល្អឯកប្លែកវិចិត្រ ធ្វើតាមប្រកិតជិតទីបាន
ប៉ុន្តែត្រឡប់ជាកេកអាន មិនបានសម្រេចដូចប្រាថ្នា ។
ចំណែកអ្នកធ្វើតែងអភិប្រាយ បរិយាយប្រែខ្វែកដោះសា
ថាទំរឿយ ១ នឿយមិនថា ឲ្យដូចចិត្តប្រាថ្នាចង់ ។
តែដេញប្រដាប់ចាប់ប្រកីដ រាប្រាសក្រជ័ងលើងយង់
គីបានមកហើយរចះតែបង់ ឥឡូវបន្ទន់រកជ្រងទៀត ។

### ៧៤- ដេញទាន់, កុំដាច់កែង

ពាក្យនេះជាពាក្យពោលបង្អាក់

សម្រាលទោសមនុស្សមានគ្រោះថ្នាក់ ត្រូវអ្នកដទៃនិយាយថ្នាំ ។
ដូចអ្នកណាមួយបានជាខុស កំហុសណាមួយដោយគាំងការ
មានអ្នកមួយទៀតតៀតសួរពន់ ដូញ់ដួលខ្លាំង ១ ដោយពាក្យស្មៀន ។
ហើយអ្នកមួយទៀតពោលបន្ទន់ ថា "យើ! ដេញទាន់កុំដាច់កែង
ថាកែតិចតួចតន់ឃើញស្ដែង តាំងពុំដាច់កែងដល់ណាទៀត ។

## ៧៥. ដៃខ្លីទៅប្រវាឱបភ្នំ

ពាក្យនេះបោរាណលោកពោលឃាត់

ឲ្យយើងទាំងឡាយបេះដូងទាត់ កុំឲ្យភ្លាំងភ្លាត់ហួសមាឌប្រាណ ។
ដូចកល់វិជ្ជាសម្បត្តិខ្លួន មិនសូវមាំមួនកុំគាប់ហាន
ធ្វើការធំៗ លើសប្រមាណ ក្រែងប៉ាន់ជំនៀលថា “មិនសម” ។
គេថា “អ្នកនេះមានដៃខ្លី មិនសមបើបីហានឱបភ្នំ”
ហេតុនេះបោរាណពោលចាំៗ ថាកុំឱបភ្នំនាំលំបាក ។

## ៧៦ – ដំរីខ្វាក់ទ្រម៉ក់ធ្លាក់

ពាក្យនេះអ្នកប្រាជ្ញលោកប្រឌិត

ពីសិស្សនិងគ្រូតាមដោយពិត ឲ្យយើងពិនិត្យគិតសេចក្ដី ។
គ្រូដូចទ្រម៉ក់អ្នកបង្ហាត់ ឯសិស្សលោកទាត់ដូចដំរី
បើសិស្សល្ងង់ខ្លៅធ្វើខុសអ្វី គ្រូមិនជេរស្ដីប្រដៅសោះ ។
ខ្ញានខ្វះដៃវៃខុសផ្លូវ មិនត្រូវគន្លងធម៌ចំពោះ
កាលសិស្សចូលមកសួរពីគ្រោះ គ្រូនោះក៏ប្រាប់ដោយស្មានៗ ។
នោះបើភ្លាត់ខុសចាកការពិត ក៏បេះតែមតឲ្យតែបាន
ខ្លាចគេថាល្ងង់ទើបបំពាន និមានប្រាប់សិស្សដោយអំនួត ។
បែបនេះបុរាណលោកទុកដាក់ ដូចដំរីខ្វាក់ទ្រម៉ក់ធ្លាក់
គ្រូណាចេះច្រើនគេមិនអួត គេប្រឹងប្រកួតយកការពិត ។

### ៧៧- ដាំដើមក្រាចមិនប្រមាណឆ្នាំង

ពាក្យនេះប្រាជ្ញចាស់លោកពោលមក
ឲ្យយើងជាន់ក្រោយចេះលៃលក   រិះរកឧបាយតាក់តែងការ ។
ឲ្យល្មមប្រមាណប្រាណអត្តភាព   មិនខ្ពស់មិនទាបមានខ្លឹមសារ
ឲ្យប៉ុនប្រសប់តាក់តែងការ   ឲ្យកើតអស្ចារ្យល្អប្រពៃ ។
អ្នកណាតាក់ការល្មមប្រមាណ   អ្នកនោះសុខសាន្តមានជោគជ័យ
អ្នកផងសរសើរថាចេះលៃ   កាញ់តែមួនមាំសមចំណាប់ ។
អ្នកណាតាក់ការលើសចំពោះ   ដែលខ្លួនប៉ុនបេះពីដើមស្រាប់
ឬលើសកម្លាំងសម្បត្តិទ្រព្យ   បើនាប់ប្រសើរមិនជាអ្វី ។
តែបើមិនគាប់មិនបានផល   នោះនាំអំពល់អាប់សេរី
អ្នកផងតិះដៀលនិយាយស្តី   ពាក្យមិនគប្បីស្វាក់កំបាំង ។
ជា "ហេតុដូចម្ដេចដាំដើមក្រាន   មិនគិតប្រមាណសំនួនឆ្នាំង"
ទើបបានប្រាជ្ញចាស់ប្រៀបទុកតាំងរឿងឆ្នាំងដើមក្រានឲ្យបានដឹងៗ

### ៧៨- ហានស្លក់ក្លរប្រាជ្ញា

ពាក្យនេះលោកពោលបណ្តុះចិត្ត
ឲ្យកើតសទ្ធាកើតគំនិត   រិះគិតជឿជាក់ដោយប្រាជ្ញា ។
ហានស្លូតជះហានក្នុងបរលោក   អស់លោកអ្នកប្រាជ្ញតាំងសាសនា

សំដែងថ្លែងគុណគុណគម្រោ　　តម្ពីដើកាថាមានពិត ។

អ្នកមានប្រាជ្ញាគួរគិតយោគ　　ជឿលោកសំដែងថែងសំគួសិទ្ធ

ជឿហើយកុំភ្លេចត្រូវប្រឹងគិត　　ប្រព្រឹត្តធ្វើតាមសីលភាវនា ។

សង្រួមខ្លួនកាយវាចាចិត្ត　　ឲ្យល្អសុចរិតគ្រប់ ៗ គ្នា

ប្រាជ្ញានៅកើតឋានសួគ៌ា　　ដែលជាទីឋានសម្រាន្តចិត្ត ។

៧៩- ឌុកាជាងរំអុកជាំកើតទុក្ខឥតអំពើ

ពាក្យនេះជាពាក្យពោលស្ដីថា

ឲ្យអ្នកដែលបានពោលវាចា　　នាំឲ្យអាចិត្តអ្នកស្ដាប់ ។

ដូចមានអ្នកម្នាក់គេនិយាយ　　អោពោយយ៉ាងខ្ជួរគាប់

ហើយមានអ្នកម្នាក់និយាយផ្ទុយ　　ម្ទាប់ពាក្យល្អគេឮគត់ទៅ ។

ដោយពាក្យផ្ដេសផ្ដាសឥតប្រយោជន៍　　នាំឲ្យផ្សាភ្ជាប់កើតយោរយៅ

ធ្វើឲ្យអ្នកពោលការពាក់ប្រើ　　នឹងនៅប្រក៏ល្អពុំបាន ។

វាចាថែបនេះលោកពោលទុក　　ថានាំអុកខ្ជួបសាមាឲ្យ

នាំឲ្យអ្នកស្ដាប់កើតរំខាន　　ឥតបានប្រយោជន៍ប្រពៃឡើយ ។

៨០- វុឌ្ឍិតរអ្នកឯគរតែផ្ញើការ

ពួកមនុស្សនានាដែលកើតមក

កែងមានគំនិតគិតផ្លែលង　　ស្វែងរកសេចក្ដីសុខរក់រេង ។

អស់អ្នកដែលមេរៀនពុំចាំបាន  នៅតែក្រោកព្រួយបង់បានរៀន
ពួកអ្នកដែលបានសុំរៀនលើសគេ  តែបង់បានប្រែថាតំនរ ។
កំពុងរៀនស្រួលក្រែលកគ្នា  បើក្បាលណាគេឲ្យពារ
ថា "ឲ្យបានសុំ" នេះត្រូវគេ  ស្មោះស ទឹងតែនោះពុំទាន ។
ព្រោះខ្លួនត្រូវការហើយគេឲ្យ  មកជាអំណោយដោយស្មោះគ្រប់
ត្រូវតាមចំនងខ្លួនបានបាន  នឹកស្មានថាខ្លួនទីមានគុណ ។
ដូចពាក្យបុរាណបានពោលមក  ថា "គេឯសុំសបានឈឺងាប់"
អ្នកគេសំគាល់ថាខ្លួនខាត  ជាគុណប្រសើរដូចពុំគួរប៊ន ។

៨១ - ព្រោះនាំខុសផ្លូវតែងនៅអន្តរាយ

ពាក្យនេះជាពាក្យលោកអ្នកប្រាជ្ញ

សំដែងឲ្យដឹងមានបំណង  ឲ្យគេប្រយ័ត្ននាំគេត្រូវផ្លូវ ។
អ្នកណានាំគេក្នុងពិទ្យ  គិតយកតាមពិតតាមត្រឹមត្រូវ
បើបេះតែងទៅដើរបួរ ។  ខឹងកើតអាក្រក់ដល់គ្នា ។
ឯអ្នកណានាំខុសពិទ្យ  ឲ្យត្រូវពិត ៗ តាមគម្រោង
ពោលគឺគម្ពីរព្រះសាសនា  លោកថានឹងបានអន្តរាយ ។
ទាំងខ្លួនអ្នកនាំនឹងអ្នកស្ដាប់  ព្រោះខុសគម្រាប់ផ្លូវគ្រោះឆ្ងាយ
ដែលប្រាជ្ញបុរាណលោកអធិប្បាយ ទុកក្ដាប់ទៅជាមិនបានសុខ ។

រឿងនេះសមដូចសុភាសិត   ពោលណាប្រឌិតទៀតមួយមុខ
ថា "លិចទាំងផង់លិចទាំងក្អម"   បានទុក្ខផងព្រោះនាំគេ ។

## ៨៤ - គសំពៅកុំស្ដាយដែក

ពាក្យនេះអ្នកប្រាជ្ញលោកទូន្មាន

ឲ្យយើងទំរុកខំព្រួន   ធ្វើការដែលបានផលយ៉ាងឯក
បើធ្វើការណាក្ដីចំណាយ   ត្រូវតែហ៊ានចាយទ្រព្យច្រើនអនេក
ដូចគសំពៅកុំស្ដាយដែក   បំបែកការនោះឡើងកើតទៅ ។
បើសាញ្ញាប្រផាញ់មិនហ៊ានចាយ   នោះត្រូវដូចអ្នកគសំពៅ
ស្ដាយដែកមិនហ៊ានចាយធ្វើទៅ   សំពៅមិនបានសម្រេចឡើយ ។

## ៨៥ - តក់ៗដូចទឹកក្លោក, ពីការឡើងសោកពេញបំពង់

ពាក្យនេះអ្នកប្រាជ្ញប្រដៅ

ឲ្យខំសន្សំទ្រព្យវិជ្ជា   គួរនាដូចការទឹកក្លោកស្រក់ ។
ទឹកទ្រព្យធនវិជ្ជា   នានាក្ដីៗមិនលោក្រក់
ឲ្យរឿយដូចតល់ទឹកក្លោកស្រក់   តក់ៗញយៗចូលបំពង់ ។
ឯទ្រព្យវិជ្ជាក៏ដោះឯង   រើចំនួនខ្ជិលឥតការង់
នឹងបានមានគ្រប់មិនយូរលង់   ខុសក្លូនកុំតិតរឿងកុំខានឡើយ ។

៨ - ត្រូវតាមដេកផ្លូវ ស្រូវៗដល់ផ្ទះ

ពាក្យនេះបុរាណលោកពោលប្រាប់

កំហុសអ្នកធ្វើការប្រញាប់ ទឹងប្រាប់កាន់សង្ស័យអ្នកក្រោយ ៗ
ជាអ្នកដែលធ្វើអ្វីគួរការ គួរក្លាងច្រើនទាញអ្នកមុខ ៗ
ដែលគេទ្រាំធ្វើបែបទ្រុយ ៗ អន្តរាយតែធ្វើត្រូវទំនង ៗ
ផម្មតាការធ្វើប្រញាប់ពេកសុំ រមែងតែងផ្លាស់ធ្វើច្រើនដង
ព្រោះធ្វើមុនខុសធ្វើក្រោយសង ដល់ធ្វើច្រើនដងទៅជាយឺត ៗ
ឯការនៃអ្នកដែលយឺតស្រាប់ ច្រើនស្អាតបំណាប់ព្រោះធ្វើស្បឹត
អ្នកផងគន់មើលឃើញថាយឺត មុឹត ៗ ក៏មែនតែល្អល្អះ ៗ
ហេតុនេះបុរាណពោលតម្រែ ថា "ត្រូវដេកផ្លូវ ស្រូវដល់ផ្ទះ"
ជាពាក្យដែលពើរមិនគួរលះ គួរចាំស្រឡះនាំបម្រើន ៗ

៨៥ - ត្រកៗអ្នកស្រុកមាកកាជាយ

រលាស់ត្បូងឆ្ងាយមានឱកមានកាន់

ពាក្យនេះជាពាក្យពោលបញ្ចៀត

កាមិត្រក្រោយកិច្ចការឲ្យស្មុះស្មើត បន្ថែតលើការដែលធ្វើបាន ៗ
ដូចមនុស្សណាមួយមិនអ្វើក្លាង ថែបយ៉ាងត្រកៗមិនគ្មានហាន
អស់ពួកអ្នកឃើញទាំងប៉ុន្មាន គិតស្មានថាគេធ្វើមិនកើត ៗ

តែលោតែធ្វើបានកើតធាប់ ចំណាប់ចំនួនយ៉ាងក្រអើត
ទើបមានអ្នកផងពោលបន្ទើត ឲ្យបានស្ទះស្ទើតដូចបរិយាយ ។
ថា "ឃើ អើ! នេះមនុស្សត្រកៅ អស់ពួកអ្នកស្រុកផងមើលឆាយ
ប៉ុន្តែលោសគគួចខ្វាយ ធ្វើការទាំងឡាយបានសម្រេច" ។

៨៦ - ជយ យស ព្រោះព្រហើន

ពាក្យនេះអ្នកប្រាជ្ញលោកប្រឌិត

តាំងឡើងជាគោលសុភាសិត តាមហេតុដែលពិតគួរជឿបាន ។
ធម្មតាស័ក្តិយសតែងកាក់កប ដល់អ្នកចេះឆបប្រែបគ្រប់ស្ពាន
គោរពប្រណិប័តន៍ប្រយ័ត្នប្រាណ មិនហ៊ានប្រហែសធ្វេសប្រមាទ ។
មនុស្សដែលព្រហើនក្អើនហោងហោង រឹតគោរក្រអើតឡើតហួសខ្នាត
តែងជួយស័ក្តិយសលោះភាគ ព្រោះចិត្តត្បាតប្រមាទគេ

៨៧- ដោតកអឹងដៃ, ថ្ងៃអឹងដមាត់ ។

ពាក្យនេះលោកពោលតាមទំនង

អ្នកធំដែលចិត្តមិនជូជង កាលឃើញអ្នកផងធ្វើការក្បែ ។
គេបានជួយធ្វើពេញកំឡាំង ដោយតាំងចិត្តត្រូវគេប្បី
ថា យើងជួយគេខំដោកអើ គេមានសេចក្តីត្រេកអរផង ។
ព្រោះយសស័ក្តិរក់នៅថ្ងៃ • ធ្វើងដូចស្វាថ្ងៃផតមានហ្មង

នៅចំដែលដូចបំណង　អ្នកផងតែគោរពសរសើរទៀត ។
ថាមើលលោកអ្នកដ៏មានយស　ស័ក្ដិធំខ្ពង់ខ្ពស់ម្ដេចលោកទៀត
លោកមិនមកគិតតែប្រៀតប្រៀន　លោកជួយឯងទៀតនឹងប្រពៃ ។
ហេតុនេះបានណាលោកបានស្ដី　ថាមានរោគអំនៅតែថ្វី
ពួកយើងជាន់ក្រោយគួរកែខៃ　តាមន័យដែលពោលមកនេះឯង ។

៨៨-ឪកាត្រជាក់ត្រីកាំ

ពាក្យនេះអ្នកប្រាជ្ញពីបុរាណ

ប្រដៅអស់យើងទាំងប៉ុន្មាន　ឲ្យមានសន្ដានចិត្តមេត្តា ។
បេះផ្លែបេះសមបេះស្លួងត្រង　ទៅកប្អូនបងនឹងញាតិកា
ហើយគេស្រឡាញ់ពេញចិត្តា　មូលមកត្រៀបត្រាជាមិត្តភក្ដិ ។
ដូចទឹកជាទីលំនៅត្រី　លុះតែពិសីថ្វាត្រជាក់ ។
ហើយអស់ត្រីផងចូលពឹងពាក់　យកជាសំណាក់កុះកុំបាន ។
បើទឹកនោះក្ដៅពេកកន្លង　អស់ពួកត្រីផងតែ[illegible]
តែចេញលែងយកជាទីឋាន　ដោយនាពុំបានព្រោះក្ដៅក្រៃ ។
អស់ពួកបាព្រាវញាតិមិត្តនាន　បើបានមកនាំពឹងប្រសើរ
និងជនណាមួយដោយកាលីយ　តែគេក្ដៅក្រពុំ[illegible] ។
ពួកញាតិសន្ដានទាំងក្នុងក្រៅ　ក៏ក្ដៅតែចេញមិនចូលមក
អោះបើបាព្រាវដែលធ្លាប់ផ្ដក　ក៏កាចផងមកតាស្រីយផង ។

### ៨៩-ទូកទៅកំពង់នៅ

ពាក្យនេះលោកពោលជាសុភាសិត

អស់ពួកមហាជនទាំងប្រុសស្រី ដើម្បីប្រយ័ត្នឲ្យខ្ជាប់ខ្ជួន ។
ទូកបានដល់ជនក្រៅដំណាង កំពង់នោះឯងបានដល់យើង
គឺពេលណាមួយបានគេរៀន មកនៅនឹងយើងពោះថ្ងៃយប់ ។
បើអ្នកមកនោះជាមនុស្សល្អ ខ្លួនយើងនេះក៏ត្រូវសេពគប់
បើមកមិនល្អក៏បង្គប់ ប្រសប់គប់យកជាមិត្តភក្តិ ។
តែគេនេះមកហើយគេទៅៗ យើងនៅឯក្រោយនឹងត្រូវថ្នាក់
ដោយជនដែលមកនោះទម្លាក់ ប្រដាក់ទោសទុកឲ្យយើងនៅ ។
ហេតុនេះប្រាជ្ញាបុរាណលោកសំដែង ឲ្យយើងគិតតែងតាំងក្នុងក្រៅ
"ប្រយ័ត្នទូកទៅកំពង់នៅ" កុំឲ្យក្រោយសៅដល់អាត្មា ។

### ៩០-ទៅឥតគេរក, មកឥតគេហៅ

ពាក្យនេះបុរាណលោកតែង

ឲ្យយើងជាន់ក្រោយមានរបៀប ថ្ងៃថ្កុំចុះប្រៀនឡើងទៅ ។
មិនឲ្យភាគថយដោយសារអ្វី បំណាច់ទៅរកគេឥតហៅ
យើងស្តាប់ព្រោះហើយត្រូវគិតជ្រៅ កុំទៅឥតគេនាំដោយខ្លួន ។
បើជនណាមួយមានការអ្វី បើគេមិនត្រូវពឹងយ៉ាងមួន
គឺមិនពឹងពាក្យគេផ្ទាល់ខ្លួន តែខ្លួនទៅជួយយកអាសា ។

បែបនេះជួនកាលក៏បានគាប់ ជួនកាលអភ័ព្វអាប់កិរិយា
ត្រូវប្រើផងថាគាប់គ្នា ទើបចាស់លោកថាដូចខាងដើម ។

### ៩១- ចូលជើងធ្មុ ក្រាជើងក្តី

សុភាសិតនេះប្រែរក

តាមន័យបុរាណលោកពោលមក អស់យើងគួរយកជាគោលបាន ។
ជាពាក្យបន្ទាបផងស្រីប្រុស មិនឲ្យគិតខុសហួសប្រមាណ
ប្រមាថអ្នកផងមិនគិតប្រាណ កើតបានជារឿងក្ដីក្ដាំឡើយ ។
ព្រោះការក្ដីក្ដាំនាំបង្កើន ចម្រើនវេលាខោសឥតស្បើយ
ទាំងខាងដើមចុងចម្លើយ ម៉្លោះហើយតែងខាតខូចទ្រព្យ ។
ដូចគល់ត្បាល់កិនតែងរបែព្រម ទាំងលើទាំងក្រោមស៊ើ ៗ គ្នា
ហេតុនេះទើបប្រាជ្ញលោកពោលថា ដូចមាត់កាខាងដើមនោះ ។

### ៩២- ជីងលេបស្មាត់, ជីងខ្លាកាំស្រូង

ពាក្យនេះប្រាជ្ញពោលប្រៀបប្រដិត

ចំពោះអ្នកខ្ញុំតាល់គំនិត មិនដឹងប្រើគិតទៅដូចណា ។
ដូចយ៉ាងរឿងក៏អ៊ីវមួយ ដែលនាំឲ្យព្រួយក្នុងចិន្ដា
ព្រោះជារឿងកើតនៃគ្នា ដែលជារឿងទុក្ខមិនសុខសាន្ដ ។
ចំពោះលើបុត្រនឹងភរិយា ប្តីញាតកាៈ ផៅសន្តាន
នឹងថាពុំកើតស្តីពុំបាន ព្រោះពានលើពាននាំចំបែង ។

អ្នកមានរឿងឈ្នះច្រើនតែថ្វី ឮសូរហ៊ឹៗ ឃើញជាក់ស្តែង
ថា "សេះបរទៅស្ទាក់ខ្លាក់ទៅស្វែង" ឈ្នះឯងទើបប្រាជ្ញលោកចងទុក ។

### ៩៣- នៅផ្ទះម្ដាយទីទៃ, នៅព្រៃម្ដាយជាមួយ

ពាក្យនេះបុរាណពោលទៀងទាត់

ចូរអ្នកផងឲ្យហ្មត់ចត់ កំណត់ព្រមព្រៀងមូលមិត្តគ្នា ។
ក្នុងពេលដែលនាំគ្នាចេញដើរ ដំណើរចូលព្រៃឬទៅណា
ទោះបីជាមនុស្សផ្សេងមាតា ត្រូវគិតដូចជាម្ដាយជាមួយ ។
ត្រូវតែស្រឡាញ់រាប់រកគ្នា នៅក្នុងវេលាមានទុក្ខព្រួយ
ឬមានធុរៈកិច្ចអ្វីមួយ ត្រូវជួយឈឺឆ្អាលពេញកម្លាំង ។
កុំគិតយករស់តែម្នាក់ឯង គប្បីខ្នះខ្នែងក្លាហានខ្លាំង
ជាបដល់រួចគ្រោះថ្នាក់ថ្នាំង កុំបិទចិត្តទាំងនឹងគ្នាឡើយ ។
គប្បីខ្វល់ខ្វាយដូចបងប្អូន លុះលួនលូលិតកុំកន្តើយ
ឲ្យដូចភាសិតដែលពោលហើយ ទើបស្បើយអស់ទុក្ខបានសុខា ។

### ៩៤- បង់ចោយមិនរមិលច្រាណ

សុភាសិតនេះពោលទូន្មាន

ឲ្យយើងចេះដឹងស្គាល់ប្រមាណ ទៅតាមសណ្ឋានបែបភាពខ្លួន ។
ដូចព្រះសម្ពុទ្ធទ្រង់ត្រាស់ថា "មត្តញ្ញុតា" ទុកជាក្បួន
ប្រែថា "ការដឹងប្រមាណខ្លួន" ឲ្យបានសមសួនកុំឲ្យលើស ។

អ្នកកួចតូចផ្តាចកុំចើនម៉ឺង　　ជំកើន៎រីកទ្រលើសបើស
ឆ្វើកកៃនកោនសំដីឃ្លើស　• លោកហៅថា "លើសហួសប្រមាណ" ៗ
អ្នកផងគេសើចគេពេបជ្រាយ　　និយាយដើមដៀលទាំងទាន
ដូចអ្នកបង់ឲ្យយមិនមើលប្រាណ　　ទៀតបានសមសួនទីងខ្ទង់មួយ ៗ

(មានត)

## កំលាំង ៥ យ៉ាង

## យុន បណ្ណានុរក្ស ប៊ូ-ប៉ូ

រៀបរៀង

តេសកុណជាតក ចត្តាឡីសនិបាត

បុរសជាអ្នកមានអធ្យាស្រ័យធំក្នុងលោកមានកំលាំង ៥ ប្រការគឺ កំលាំងដើមដៃ ១ កំលាំងទ្រព្យ ១ កំលាំងអាមាត្យ ១ កំលាំងជាតិ ១ កំលាំងបញ្ញា ១ ។

### អធិប្បាយថា

ទី ១— កំលាំងដើមដៃ បានដល់កំលាំងកាយ ៗ នោះបើទុកជាធំខ្លាំងយ៉ាងណាក៏ដោយ ក៏ចាត់ជាកំលាំងថោកទាប ព្រោះហេតុអ្វី ព្រោះថាបណ្ដាសត្វលើផែនដី ដំរីជាសត្វមានខ្លួនធាត់ធំសម្បើមនិងមានកំលាំងខ្លាំងជាងសត្វទាំងអស់ ប៉ុន្តែដំរីបែរជាស្លាប់ដោយកំលាំងសត្វតូចមួយទៅវិញ ដ្បិតតាបមានប្រាជ្ញាឈ្លាសវៃប៉ិនប្រសប់បេះទុយកណ្ដាប ធ្វើឲ្យដំរីស្លាប់បានដោយងាយ ។

ទី ២— កំលាំងទ្រព្យ បានដល់គ្រឿងប្រដាប់សំរាប់ប្រើប្រាស់ មានប្រាក់មាសជាដើម និងអាហារភោជនមានបាយទឹកជាដើម ទ្រព្យសម្បត្តិនេះចាត់ជាកំលាំងវិសេសជាងកំលាំងកាយ ព្រោះថាទ្រព្យសម្បត្តិទាំងឡាយអាចដើម្បីទំនុកបំរុងចិត្តឬរូបកាយឲ្យសុខសប្បាយ

នឹងឲ្យមានដីកែរស់នៅបានមួយនឹងចំណាយទ្រព្យជួលមនុស្សធ្វើការងារ ជូនស្រាលជួសខ្លួនក៏បាន ។

ទី ៣– កំឡាំងអាមាត្យ បានដល់ពួកអ្នកធ្វើការគ្រប់ក្រសួង មានលោកសេនាបតីជាប្រធាន អស់លោកមន្ត្រីទាំងនោះសុទ្ធតែជាអ្នកទទួលភារៈចាត់ការត្រួតត្រាស្រុកទេសឲ្យបានសុខសាន្តត្រាណរៀបរយល្អ គឺងរក្សាការពារសត្រូវខាងក្រៅមិនឲ្យលោកមកលើខេត្រដែនបាន ប្រសិនបើមានសឹកសង្គ្រាមកើតឡើងក្នុងស្រុក ក្រុមសេនាយោធាមាត្យទាំងនោះហើយជាកំឡាំងក្នុងការច្បាំងកំចាត់សឹកសត្រូវ ហេតុនេះ កំឡាំងអាមាត្យជារបស់វិសេសធំជាងកំឡាំងកាយនឹងកំឡាំងទ្រព្យ ។

ទី ៤– កំឡាំងជាតិ បានដល់ត្រកូលក្សត្រជាត្រកូលថ្លៃថ្នូរខ្ពង់ខ្ពស់ ជាងត្រកូលទាំង ៣ គឺត្រកូលព្រាហ្មណ៍, ត្រកូលវៃស្យៈ, នឹងត្រកូលសូទ្រៈ ដ្បិតត្រកូលក្សត្រជាអ្នកគ្រប់គ្រងនគរ ជាទង់ជ័យរបស់ស្រុក ជាប្រមុខនៃប្រជាជនក្នុងប្រទេសជាតិ ហេតុនេះ ត្រកូលក្សត្រជាកំឡាំងជាតិដ៏ខ្ពង់ខ្ពស់ ជាធំវិសេសជាងកំឡាំងកាយ, ទ្រព្យ, នឹងអាមាត្យ ។

ទី ៥– កំឡាំងបញ្ញា បានដល់មនុស្សអ្នកមានប្រាជ្ញា ចេះវិជ្ជាការសិល្បសាស្ត្រនានាក្នុងលោក កំឡាំងបញ្ញានោះជាធំជាកំពូលលើកំឡាំងទាំង ៤ ខាងដើម ដ្បិតជាអ្នកមានប្រាជ្ញាឈ្លាសវៃអាចនឹងធ្វើឧបាយកលផ្លាលផ្លាញ់អ្នកល្ងង់ខ្លៅភានភាយ គាបនឹងស្វែងរកទ្រព្យសម្បត្តិចិញ្ចឹម

ដីរែកបានឆ្ងាយ ឬទឹងដីប្រឡង ឲ្យលូកកន្ត្រកស្ពានកេជការតាំងខ្លួនជាមន្ត្រី បានឆ្ងាយ ។

រួមកំឡាំងទាំង ៤ យ៉ាងនេះ ឃើញថាកំឡាំងកាយជារបស់ជាន់ទាបបំផុត កំឡាំងបញ្ញាជារបស់ជាន់ខ្ពស់បំផុត មានរឿងក៏ជាគ្រឿងពន្យល់ឲ្យឃើញកំឡាំងកាយនឹងកំឡាំងបញ្ញាដូចបានពណ៌នាតទៅនេះៈ

## រឿងសត្វតាបសម្លាប់ដំរីសារ (១)

មានដំរីសារ ១ ដើររកស៊ីកនៅព្រៃដាច់ចេញពីហ្វូងតែម្នាក់ឯង ថ្ងៃ ១ បានដើរទៅជួបប្រទះនឹងមេតាប កំពុងតែក្រាបក្រុងកូនទៅកណ្ដាលផ្លូវដែលខ្លួនដើរ មេតាបនិយាយអង្វរដំរីថា "សូមលោកករុណាមេត្តាកុំដើរជាន់កូនខ្ញុំ" ដំរីមិនព្រមទទួលយកពាក្យអង្វរក៏ឆ្លើយតបទៅវិញថា អញមិនដឹងមិនស្គាល់ការណាទេ អញចេះតែដើរជាន់ ស្លាប់ការណាក៏ដោយ តាបឯងខ្លួនតូចប៉ុណ្ណេះនឹងធ្វើអ្វីអញបាន បើទុកជាតាបឯងមានចំនួនច្រើនដល់ទៅ ១ ម៉ឺន ក៏អញជាន់ឈ្លីនឹងជើងធ្វើអញតែម្ដងឲ្យស្លាប់ល្អិតល្អោចអស់ឥតសល់មួយដែរ ដំរីថាតែប៉ុណ្ណេះហើយក៏ដើរជាន់កូនតាបខ្ទេចខ្ទីស្លាប់អស់ទៅ មេតាបឃើញកូនស្លាប់ដូច្នោះហើយ ក៏កើតទុក្ខក្ដៅក្រហាយសោកស្ដាយកូនណាស់ ទើបហើរទៅទំលើមែកឈើហើយនិយាយ

---

១ លដុកិកជាតក បញ្ចកនិបាត ធរណិកុម្ភាលវគ្គទី ១ ។

ប្រាប់ដំរីថា "ដំរីឯងហ៊ានមើលងាយអញ ដ្បិតតែឃើញអញខ្លួនតូច
កំលាំងតិច ប៉ុន្តែឯងមិនទាន់ដឹងកំលាំងបញ្ញាអញទេ ចាំមើលអញនឹង
ធ្វើសងសឹកដល់ឯងវិញ" មេថាបនិយាយរួចហើយក៏ហើរទៅរកពឹងសត្វ
ក្អែកឲ្យទៅចឹកភ្នែកដំរីឲ្យបែកដាច់ទៅទាំងសងខាង ក្អែកក៏ទទួល
យកអាសា ទើបមេថាបទៅពឹងសត្វរុយទៀត ឲ្យរុយពងដាក់ភ្នែកដំរី
ឲ្យកើតជាដង្កូវពុះកួរភ្នែកទាល់តែខ្វាក់ទាំងពីរ កាលដំរីនោះឈឺភ្នែកបែក
ខ្វាក់ទាំងពីរនឹងមើលផ្លូវមិនឃើញហើយ ក៏កើតទុក្ខវេទនា លំបាកនឹង
រកស្មៅស៊ី នឹងរកទឹកផឹកក៏ពុំបាន មេថាបឃើញដំរីខ្វាក់ភ្នែកដូច្នោះហើយ
ក៏ទៅពឹងសត្វកង្កែបឲ្យឡើងទៅយំលើកំពូលភ្នំ ដំរីឮកង្កែបយំ មានចិត្ត
ត្រេកអរដោយសំគាល់ថាមានត្រពាំងទឹក ទើបដើរឡើងទៅលើកំពូលភ្នំ
កាលដំរីទៅដល់កំពូលភ្នំហើយ កង្កែបលោតចុះទៅយំក្នុងជ្រោះវិញ
ដំរីដើរតាមសំឡេងកង្កែបទៅទៀត លុះដល់មាត់ជ្រោះក៏រអិលជើងរមៀល
ធ្លាក់ទៅក្នុងជ្រោះស្លាប់ទៅ ឯមេថាបបានដឹងថាដំរីស្លាប់ហើយ ក៏មាន
ចិត្តត្រេកអរណាស់ ។

១៨-១០-៦៦

ប៊ូ · ប៊ី

អរិយសច្ចជាពុទ្ធភាសិត

## ព្រះអាចារ្យ ប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តមក)

## មានបុគ្គលត្រាស់ដឹងអរិយសច្ច ទាំងក្នុងអតីតកាល អនាគតកាលនិងបច្ចុប្បន្នកាល

ម្នាលភិក្ខុទាំងឡាយ ! ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ កុលបុត្តទាំងឡាយឯណាមួយ ចេញចាកផ្ទះ ហើយបួសក្នុងអនាគារិយវិស័យ តែងបានត្រាស់ដឹងតាមពិត, កុលបុត្តទាំងឡាយនោះតែងត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ ! ក្នុងអនាគតកាលដ៏មានមកអស់កាលយូរលង់ កុលបុត្តទាំងឡាយឯណាមួយ នឹងចេញចាកផ្ទះហើយបួសក្នុងអនាគារិយវិស័យ តែងនឹងបានត្រាស់ដឹងតាមពិត កុលបុត្តទាំងឡាយនោះ តែងនឹងត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ ! ក្នុងបច្ចុប្បន្នកាលឥឡូវនេះ កុលបុត្តទាំងឡាយឯណាមួយ ចេញចាកផ្ទះហើយបួសក្នុងអនាគារិយវិស័យ តែងត្រាស់ដឹងតាមពិត, កុលបុត្តទាំងឡាយនោះ តែងត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ។ អរិយសច្ចទាំងឡាយ ៤ ប្រការនោះតើដូចម្តេច ? អរិយសច្ចទាំងឡាយ ៤ ប្រការនោះគឺ សេចក្តីទុក្ខជាសេចក្តីពិតដ៏ប្រសើរ ១ ហេតុប្រជុំកើតឡើងនៃទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១. ធម៌ជាគ្រឿង

រំលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១, សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ជាសេចក្តីពិតដ៏ប្រសើរ ១ ។

មហាវារ សំ: ១៩ - ៥២១ - ១៦៥៣

## ទ្រង់ត្រាស់ថាចូរនៅស្ងាត់បាកអារម្មណ៍ នឹងត្រាស់ដឹងអរិយសច្ច

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ ចូរព្យាយាមនៅក្នុងទីស្ងាត់បាកអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ! ភិក្ខុដែលនៅស្ងាត់បាកអារម្មណ៍តែងដឹងច្បាស់តាមពិត ។ ដឹងច្បាស់តាមពិតនូវអ្វី? ដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរព្យាយាមនៅក្នុងទីស្ងាត់បាកអារម្មណ៍ចុះ ។ ម្នាលភិក្ខុទាំងឡាយ! ភិក្ខុដែលនៅស្ងាត់បាកអារម្មណ៍ តែងដឹងច្បាស់តាមពិត ។

មហាវារៈ សំ. ១៩-៥២០-១៦៥៤

## ទ្រង់ត្រាស់ថាចូរចំរើនសមាធិ នឹងត្រាស់ដឹងអរិយសច្ចតាមពិត

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរចំរើនសមាធិចុះ ។ ម្នាលភិក្ខុទាំងឡាយ! ភិក្ខុមានចិត្តជាសមាធិហើយ តែងដឹងច្បាស់តាមពិត ។ ដឹងច្បាស់តាមពិតនូវអ្វី? ដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុ

ប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិ
ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយ
ចូរចំរើនសមាធិចុះ ។ ម្នាលភិក្ខុទាំងឡាយ ! ភិក្ខុមានចិត្តជាសមាធិហើយ
តែងដឹងច្បាស់តាមពិត ។

មហាវ. សំ. ១៩ - ៥២៧ - ១៦៥៦

## ចិត្តជាសមាធិហើយ
## ដឹងនូវអរិយសច្ចច្បាស់លាស់ ដូចឃើញរបស់ក្នុងទឹកថ្លា

កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាស
ចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង
មិនញាប់ញ័រដោយអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ
ដើម្បីអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងក្ស័យនៃអាសវៈទាំង
ឡាយ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា : "នេះទុក្ខ នេះហេតុប្រជុំ
កើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរ
ទៅកាន់ទីរំលត់ទុក្ខ" ដឹងច្បាស់តាមពិតថា : "នេះអាសវៈ នេះហេតុ
ប្រជុំកើតឡើងនៃអាសវៈ នេះធម៌ជាគ្រឿងរំលត់នៃអាសវៈ នេះសេចក្ដី
ប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់អាសវៈ" ។ កាលបើភិក្ខុនោះ ដឹងយ៉ាង
នេះហើយ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង

ចាកភវាសវៈផង ចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា៖ "ចិត្តរបស់អាត្មាអញផុតស្រឡះហើយ" ដឹងច្បាស់ថា៖ "កំណើតអស់ហើយ ព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តហើយ សោឡសកិច្ចអាត្មាអញក៏បានធ្វើស្រេចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ" ។

ម្នាលភិក្ខុទាំងឡាយ! ដូចជាអន្លង់ទឹកលើកំពូលភ្នំដែលថ្លាស្អាត ឥតមានកករល្អក់ បុរសម្នាក់ខាងចក្ខុឈរនៅលើច្រាំង នឹងបានមើលឃើញខ្យងនិងគ្រំខ្លះ ដុំក្រួសនិងដុំថ្មខ្លះ ហ្វូងត្រីដែលកំពុងបំកាំងខ្លះ ហែលទៅមកខ្លះក្នុងអន្លង់ទឹកនោះ ។ បុរសនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា "អន្លង់ទឹកនេះឯងថ្លាស្អាត ឥតមានកករល្អក់ ខ្យងនិងគ្រំទាំងនេះក្តី ដុំក្រួសនិងដុំថ្មទាំងនេះក្តី ហ្វូងត្រីទាំងនេះកំពុងសំកាំងខ្លះ ហែលទៅមកខ្លះក្តី ក្នុងអន្លង់ទឹកនោះយ៉ាងណាមិញ, ម្នាលភិក្ខុទាំងឡាយ! ភិក្ខុដឹងច្បាស់តាមពិតថា៖ "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់ថា" "កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៅទៀត មិនមានក៏យ៉ាងនោះដែរ" ។

## បើប្រព្រឹត្តត្រូវតាមគន្លងផ្លូវ

## កិរិយាទៅកាន់ព្រះនិព្វានស្រួលប្រៀបដូចឈើអណ្តែតទឹក

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយឃើញសំណាក់ឈើមួយដើមធំនុះ កំពុងអណ្តែតតាមខ្សែទឹកទន្លេគង្គាឬទេ? ក្រាបទូល ឃើញ ព្រះអង្គដ៏ចំរើន ។ ម្នាលភិក្ខុទាំងឡាយ! ថាបើសំណាក់ឈើនេះមិនបោកទៅជាប់ត្រើយខាងអាយទេ ឬត្រើយខាងនាយទេ មិនលិចទៅពាក់កណ្តាលទេ មិនគៀងលើគោកទេ មិនមានមនុស្សចាប់យកទេ មិនមានអមនុស្សចាប់យកទេ មិនមានទឹកគួចយកទេ មិនស្អុយបណ្តូលទេ ម្នាលភិក្ខុទាំងឡាយ! បើមានហេតុដូច្នេះ សំណាក់ឈើនេះ មុខជាអណ្តែតទៅកាន់សមុទ្រ ទំនោរទៅកាន់សមុទ្រ ទំនាលទៅកាន់សមុទ្រ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ! ព្រោះថាខ្សែទឹកទន្លេគង្គាហូរទៅកាន់សមុទ្រផង ទេរទៅកាន់សមុទ្រផង ជំពាលទៅកាន់សមុទ្រផង ទាំងឧបមាយ៉ាងណា, ម្នាលភិក្ខុទាំងឡាយ! ឧបមេយ្យ អ្នកទាំងឡាយ បើអ្នកទាំងឡាយមិនជាប់ត្រើយខាងអាយទេ ទៅត្រើយខាងនាយទេ មិនលិចទៅពាក់កណ្តាលទេ មិនគៀងទៅលើគោកទេ មិនមានមនុស្សកាន់យកទេ មិនមានអមនុស្សកាន់យកទេ មិនមានទឹកគួចយកទេ មិនស្អុយផង់ទេ, ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយ នឹងហូរទៅកាន់ព្រះនិព្វាន នឹងទេរទៅកាន់ព្រះនិព្វាន នឹងជំពាលទៅ

កាន់ព្រះនិព្វាន ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ! ព្រោះថា សេចក្តីយល់ត្រូវនឹងហូរទៅកាន់ព្រះនិព្វាន ទំរៀរទៅកាន់ព្រះនិព្វាន នឹងដំកល់ទៅកាន់ព្រះនិព្វាន ៗ

ម្នាលភិក្ខុទាំងឡាយ! ពាក្យថា: "ត្រើយខាងអាយ" ជាឈ្មោះអាយតនៈ ៦ ខាងក្នុង" ពាក្យថា: "ត្រើយខាងនាយ" ជាឈ្មោះអាយតនៈទាំងឡាយ ៦ ខាងក្រៅ" ពាក្យថា: "លិចនៅពាក់កណ្តាល ជាឈ្មោះនន្ទិរាគៈ សេចក្តីត្រេកអរក្រើតក្រើន" ពាក្យថា "គៀងលើគោក ជាឈ្មោះអស្មិមានៈ" ម្នាលភិក្ខុ! ពាក្យថា: មនុស្សចាប់ដូចម្តេច? ម្នាលភិក្ខុ! ភិក្ខុក្នុងសាសនានេះនៅច្រឡំបល់ដោយគ្រហស្ថទាំងឡាយ ក្រើតក្រើនជាមួយគ្នា សោកសៅជាមួយគ្នា បើគ្រហស្ថបានសុខ ខ្លួនក៏បានសុខផង បើគ្រហស្ថបានទុក្ខ ខ្លួនក៏បានទុក្ខផង បើគ្រហស្ថមានកិច្ចការត្រូវធ្វើកើតឡើង ភិក្ខុក៏ជួយធ្វើកិច្ចការគ្រហស្ថនោះផង ម្នាលភិក្ខុ! នេះពាក្យថា: មនុស្សចាប់ ៗ ម្នាលភិក្ខុ! ពាក្យថា: អមនុស្សចាប់ ដូចម្តេច? ម្នាលភិក្ខុ! ភិក្ខុក្នុងសាសនានេះ ប្រព្រឹត្តព្រហ្មចរិយធម៌ ប្រាថ្នាទៅកើតក្នុងទេវនិកាយពួកឯណានីមួយ ដោយគិតថា: "ដោយសីលនេះក្តី ដោយវត្តប្រតិបត្តិនេះក្តី ដោយតបធម៌នេះក្តី ដោយព្រហ្មចរិយធម៌នេះក្តី សូមឲ្យអាត្មាអញបានទៅកើតជាទេវតា ម្នាក់នោះ ឲ្យវិសេសជាងទេវតាទៅទៀត"; ពាក្យថា: "វិលក្តួច" ជាឈ្មោះកាមគុណទាំងឡាយ ៥

ប្រការ, ម្នាលភិក្ខុ! ពាក្យថា: ស្អុយបណ្ឌូល តើដូចម្តេច? ម្នាលភិក្ខុ! ភិក្ខុណាមួយក្នុងសាសនានេះ ទ្រុស្តសីល, មានធម៌លាមក មិនស្អាត មានអាការៈគួរស្ញើស បិទការងារខ្លួនត្រូវធ្វើទុក មិនមែនជាសមណៈក៏ប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនព្រហ្មចារី ក៏ប្តេជ្ញាខ្លួនថាជាព្រហ្មចារី ជាមនុស្សស្អុយក្នុង ជាមនុស្សជោកជាំដោយកាម ជាមនុស្សទ្រុឌកាម ម្នាលភិក្ខុ! នេះភាពនៃបុគ្គលស្អុយក្នុង ។

សឡាយតនៈ សំ. ១៨ - ២២៣ - ៣២២

## ការត្រាស់ដឹងនូវអរិយសច្ចមិនមែនផុតវិស័យសត្វ ហេតុនេះទើបមានព្រះអរិយបុគ្គលច្រើនណាស់

ម្នាលវច្ឆៈ! ពួកភិក្ខុសាវករបស់តថាគត ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដ៏មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយអរិយាបថទាំង ៤ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ទេ, ម្នាលវច្ឆៈ! ដោយពិតមានច្រើនលើសប្រមាណណាស់ ... ។

ម្នាលវច្ឆៈ! ពួកភិក្ខុនីដែលជាសាវិការបស់តថាគត ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដ៏មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយអរិយាបថទាំង ៤ មិនមែនមានត្រឹមតែ ១០០, ២០០,

៣០០, ៤០០, ៥០០ ។ល។, ម្នាលវច្ឆៈ! ដោយពិត មានច្រើនលើសប្រមាណណាស់ ... ។

ម្នាលវច្ឆៈ! ពួកគ្រហស្ថដែលជាឧបាសកដែលជាសាវករបស់តថាគត ស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ជាឧបបាតិកកំណើត (អនាគាមីបុគ្គល) នឹងបរិនិព្វានក្នុងទីនោះ មិនបានត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈដែលជាចំណែកខាងក្រោម ៥, មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ។ល។, ដោយពិត មានច្រើនលើសប្រមាណណាស់ ... ។

ម្នាលវច្ឆៈ! ពួកគ្រហស្ថជាឧបាសក ដែលជាសាវ័ករបស់តថាគត ស្លៀកដណ្តប់ស នៅបរិភោគកាម តែជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីពោលថាអ្វីៗ (មិនពោលដោយសេចក្តីសង្ស័យថា:នេះអ្វីៗ) ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា, មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ។ល។, ដោយពិត មានច្រើនលើសប្រមាណណាស់ ... ។

ម្នាលវច្ឆៈ! ពួកគ្រហស្ថជាឧបាសិកា ដែលជាសាវិការបស់តថាគត ស្លៀកដណ្តប់ស ជាសព្រហ្មចារិនី ជាឧបបាតិកកំណើត (អនាគាមី) នឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់

ទៅនៃសំយោជនៈជាចំណែកខាងក្រោម ៥, មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ទេ, ដោយពិតមានច្រើនលើសប្រមាណណាស់ ... ។

ម្នាលវច្ឆៈ! ពួកគ្រហស្ថជាឧបាសិកា ដែលជាសាវិការបស់តថាគត ស្លៀកដណ្តប់ស នៅបរិភោគកាម ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ប្រាសចាកសេចក្តីសង្ស័យ ប្រាសចាកសេចក្តីពោលថាអ្វីៗ (មិនពោលដោយសេចក្តីសង្ស័យថាដូចម្តេចៗ) ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា, មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ទេ, ដោយពិតមានច្រើនលើសប្រមាណណាស់ ... ។ ម. ម. មហាវច្ឆគោត្តសូត្រ ២៤ - ២៨ - ១៦.

បទទី ៥

## ប្រភេទអរិយសច្ច

រូបអរិយសច្ចមានតែមួយយ៉ាង តែពាក្យអធិប្បាយមានច្រើន

ម្នាលភិក្ខុទាំងឡាយ "នេះសេចក្តីពិតដ៏ប្រសើរគឺទុក្ខ" ជាពាក្យដែលតថាគតបញ្ញត្តហើយ តែក្នុងសេចក្តីពិតនោះ មានពាក្យអធិប្បាយច្រើនប្រមាណមិនបាន មានព្យញ្ជនៈច្រើនប្រមាណមិនបាន មានកិរិយាចែកឲ្យពិស្តារច្រើនប្រមាណមិនបាន ដោយបរិយាយថា "សេចក្តីពិតដ៏ប្រសើរគឺទុក្ខនេះ មានប្រការដូច្នេះផងៗ" ។

ម្នាលភិក្ខុទាំងឡាយ! “នេះសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ” ជាពាក្យដែលតថាគតបញ្ញត្តហើយ, តែក្នុងសេចក្តីពិតនោះ មានពាក្យអធិប្បាយច្រើនប្រមាណមិនបាន មានព្យញ្ជនៈច្រើនប្រមាណមិនបាន មានកិរិយាបែកឲ្យពិស្តារច្រើនប្រមាណមិនបាន ដោយបរិយាយដូច្នេះថា: “សេចក្តីពិតដ៏ប្រសើរ គឺហេតុប្រជុំកើតឡើងនៃទុក្ខនេះមានប្រការដូច្នេះផងៗ” ។

ម្នាលភិក្ខុទាំងឡាយ! “នេះសេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ” ជាពាក្យដែលតថាគតបញ្ញត្តហើយ, តែក្នុងសេចក្តីពិតនោះ មានពាក្យអធិប្បាយច្រើនប្រមាណមិនបាន មានព្យញ្ជនៈច្រើនប្រមាណមិនបាន មានកិរិយាបែកឲ្យពិស្តារច្រើនប្រមាណមិនបាន ដោយបរិយាយដូច្នេះថា: “សេចក្តីពិតដ៏ប្រសើរ គឺធម៌ជាគ្រឿងរំលត់ទុក្ខនេះ មានប្រការដូច្នេះផងៗ” ។

ម្នាលភិក្ខុទាំងឡាយ! “នេះសេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ” ជាពាក្យដែលតថាគតបញ្ញត្តហើយ តែក្នុងសេចក្តីពិតនោះ មានពាក្យអធិប្បាយច្រើនប្រមាណមិនបាន មានព្យញ្ជនៈច្រើនប្រមាណមិនបាន មានកិរិយាបែកឲ្យពិស្តារច្រើនប្រមាណមិនបាន ដោយបរិយាយថា: “សេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខនេះមានប្រការដូច្នេះផងៗ” ។

ឧទាហរណ៍: សំ. ១៩ . ៤៣៩ . ១៦៩៦ (មានត)

## សេចក្ដីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យ បានជូនដំណឹងក្នុងសៀវភៅទស្សនាវដ្ដីកម្ពុជសុរិយា លេខ ៩ ខែសេបតមប្រ៍ ១៩៤៨ ថា រឿងឯកសហស្រាត្រី នឹងមានចុះផ្សាយក្នុងទស្សនាវដ្ដីលេខ ១០ ប្រចាំខែឧកតូប្រ៍ ១៩៤៩ នេះជាដើមរឿងទៅ ប៉ុន្តែឥឡូវនេះគាត់ខានវិញទេ នឹងចាំចុះផ្សាយក្នុងទស្សនាវដ្ដីឆ្នាំ ១៩៤៦ ចាប់តាំងពីសៀវភៅលេខ ១ ប្រចាំខែយ៉ាំងវីយេ ជាដើមតទៅ ដើម្បីឲ្យមានដំណើរជាប់តាក់តងហូរហែក្នុងឆ្នាំជាមួយគ្នាតែម្ដង ។